សេចក្តីផ្តើម

ក្រោមឧត្តមមគ្គុទេសក៍ និងចក្ខុវិស័យដឹកនាំប្រាកដនិយមប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយជោគជ័យជាផ្លែផ្កា នូវយុទ្ធសាស្ត្រចតុកោណដែលបានដាក់ចេញជាបន្តបន្ទាប់ ព្រមទាំងបាននិងកំពុងបន្តដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដើម្បីពង្រឹង និងពង្រីកសមិទ្ធផលនានា ដែលសម្រេចបានឱ្យកាន់តែមានការរីកចម្រើនលើគ្រប់វិស័យបន្ថែមទៀត។ក្នុងរយៈពេលជាងពីរទសវត្សន៍ចុងក្រោយនេះ កម្ពុជាបានរក្សានូវកំណើនសេដ្ឋកិច្ចខ្ពស់ និងជាប្រទេសដែលសម្រេចបាននូវជោគជ័យដ៏ល្អប្រសើរក្នុងការកែទម្រង់ស៊ីជម្រៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពប្រជាជនឱ្យកាន់តែប្រសើរឡើង តាមរយៈការបែងចែកកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន, ការបង្កើតការងារថ្មីៗបន្ថែមជូនប្រជាជន, ការធានាបាននូវសមធម៌សង្គម, ការផ្ទេរអំណាច និងស្វ័យភាពកាន់តែច្រើនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ ដែលជាកត្តាធ្វើឱ្យគំលាតជីវភាពរវាងអ្នកមាននិងអ្នកក្រកាន់តែខិតជិតគ្នាគួរឱ្យកត់សម្គាល់ពីមួយឆ្នាំទៅមួយឆ្នាំ។ ទោះបីជាក្នុងដើមត្រីមាសទី១ ឆ្នាំ២០២២ នេះ សេដ្ឋកិច្ចរបស់ពិភពលោកទាំងមូលរួមទាំងព្រះរាជាណាចក្រកម្ពុជាផងដែរ បានបន្តរងផលប៉ះពាល់ដោយការរាតត្បាតនៃជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរកូវីដ-១៩ (COVID-19), រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួង-ស្ថាប័នពាក់ព័ន្ធជាសេនាធិការ បានខិតខំដោយយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពក្នុងការប្រយុទ្ធប្រឆាំងទប់ស្កាត់ និងលប់បំបាត់ ជំងឺនេះឱ្យអស់ពីប្រទេសកម្ពុជា ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏បានដាក់ចេញនូវវិធានការជាបន្តបន្ទាប់ ដើម្បីជួយសម្រួល និងកាត់បន្ថយផលប៉ះពាល់លើវិស័យសំខាន់ៗមួយចំនួនដែលជាជន្ទល់សេដ្ឋកិច្ច ក្នុងគោលដៅរក្សាស្ថិរភាពសេដ្ឋកិច្ច និងធ្វើយ៉ាងណាឱ្យសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេល៩ខែ ឆ្នាំ២០២២ នេះ អាចសម្រេចបាននូវកំណើតមួយសមរម្យ ដែលជាស្ពានឈានទៅសម្រេចបាននូវគោលដៅសេដ្ឋកិច្ចជាតិឆ្នាំ២០៥០ ដែលរាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យជាក់លាក់រួចជាស្រេច។

តាមរយៈនេះ រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងបន្តធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃយ៉ាងច្បាស់លាស់លើការអនុវត្តមុខងារភារកិច្ចរបស់ក្រសួង-ស្ថាប័ននីមួយៗ សំដៅបង្កើន និងរក្សាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តកិច្ចការងារ ដោយបានតម្រូវឱ្យមានរបបរាយការណ៍ជាផ្លូវការអំពីវឌ្ឍនភាព នៃការអនុវត្តការងាររបស់អង្គភាពខ្លួន ជា**ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ** ដើម្បីរាជរដ្ឋាភិបាលមានមូលដ្ឋានពិនិត្យបូកសរុប តាមដាន និងវាយតម្លៃសមិទ្ធកម្មការងារ នៃការអនុវត្តគោលបំណងគោលនយោបាយរបស់គ្រប់ក្រសួង-ស្ថាប័ន ដែលរាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់ ព្រមទាំងអាចទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ចាត់វិធានការដោះស្រាយ និងចាត់ចែងរៀបចំផែនការជាបន្តបានទាន់ពេលវេលា។ ក្នុងន័យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏មិនខុសគ្នាពីក្រសួង-ស្ថាប័នដទៃ គឺត្រូវមានកាតព្វកិច្ចរាយការណ៍ពីវឌ្ឍនភាព នៃការអនុវត្តគោលបំណងគោលនយោបាយចំនួនពីររបស់ខ្លួនដែលរាជរដ្ឋាភិបាលបានប្រគល់ជូន គឺ១. ការពង្រឹងសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ និង២. ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ព្រមទាំងកម្មវិធីរបស់ក្រសួងចំនួនប្រាំជូនដល់រាជរដ្ឋាភិបាលជាប្រចាំផងដែរ និងតែងតែបានរៀបចំរបាយការណ៍សកម្មភាពការងាររបស់ខ្លួន និងបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីយ៉ាងទៀងទាត់ជាប្រចាំ។

របាយការណ៍សកម្មភាពការងារប្រចាំ៩ខែ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនាពេលនេះត្រូវបានរៀប-ចំឡើងតាមរយៈការប្រមូលធាតុចូលពីរបាយការណ៍សកម្មភាពការងារ នៃគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាតួអង្គអនុវត្តផ្ទាល់ យកមកពិនិត្យចងក្រង និងធ្វើអាទិភាវូបនីយកម្មសម្រួចសកម្មភាពធំៗ ដោយទាញយកចំណុចសំខាន់ៗបញ្ចូលទៅក្នុងកម្មវិធី និងអនុកម្មវិធី ជាសមត្ថកិច្ចរបស់អង្គភាពជំនាញស្របតាមគោលបំណងគោលនយោបាយរបស់ក្រសួង នឹងបង្ហាញអំពីសមិទ្ធ

ផលការងារសំខាន់ៗ ដែលអង្គភាពនីមួយៗបានខិតខំសម្រេចបាននារយៈពេល៩ខែ ឆ្នាំ២០២២នេះ ព្រមទាំងរំលេចអំពីសូចនាករដែលមិនទាន់សម្រេចបានដើម្បីជាមូលដ្ឋានពិនិត្យ តាមដាន វាយតម្លៃ និងពង្រឹងការអនុវត្តបន្តឱ្យកាន់តែមានគុណភាពបន្ថែមទៀត។ ខ្លឹមសារក្នុងផ្នែកនីមួយៗនៃរបាយការណ៍នេះ ត្រូវបានរៀបចំពណ៌នាជាសមិទ្ធផល និងសកម្មភាពគន្លឹះៗ ដែលអង្គភាពសម្រេចបានទាំងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ ក្នុងគោលដៅធ្វើយ៉ាងណាប្រមូលផ្តុំព័ត៌មានឱ្យបានពេញលេញ គ្រប់ជ្រុងជ្រោយ និងមានសារប្រយោជន៍ពីគ្រប់ផ្នែកគាំទ្រទាំងអស់របស់ក្រសួងសំដៅត្រួតពិនិត្យតាមដាន និងជំរុញការបំពេញមុខងារជាសេនាធិការរបស់រាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំនិងគ្រប់គ្រងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

១. ការគ្រប់គ្រងសេដ្ឋកិច្ច និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

ស្របតាមផែនការយុទ្ធសាស្ត្រថវិកា២០២២-២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, គោលបំណងគោលនយោបាយទី១. “ការគ្រប់គ្រងសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ” មានកម្មវិធីចំនួន២ ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយនេះ។

១.១. ការគ្រប់គ្រងសេដ្ឋកិច្ច

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគោលនយោបាយ និងអគ្គលេខាធិការដ្ឋានគណៈកម្មការផលិតភាពសេដ្ឋកិច្ចកម្ពុជា។ អគ្គនាយកដ្ឋានគោលនយោបាយមានមុខងារសំខាន់ៗ ក្នុងការរៀបចំ និងតាមដានការអនុវត្តគោលនយោបាយ និងយុទ្ធ-សាស្ត្រពាក់ព័ន្ធវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តាមដាន និងវាយតម្លៃនិន្នាការសេដ្ឋកិច្ចជាតិ តំបន់ និងពិភពលោក ក្នុងកម្រិតវិស័យធំៗ សូចនាករម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងចូលរួមចំណែកក្នុងការងារពាក់ព័ន្ធដល់ការរៀបចំគោលនយោបាយ ពាណិជ្ជកម្ម និងហិរញ្ញវត្ថុក្រៅប្រទេស និងកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ក្នុងតំបន់ និងពិភពលោក[1]។ រីឯអគ្គលេខាធិការដ្ឋានគណៈកម្មការផលិតភាពសេដ្ឋកិច្ចកម្ពុជាផ្តោតលើកិច្ចការរដ្ឋបាលនិងការងារបច្ចេកទេសសិក្សាស្រាវជ្រាវ សម្រាប់គាំទ្រកិច្ចដំណើរការរបស់គណៈ-កម្មការផលិតភាពសេដ្ឋកិច្ចកម្ពុជា។ ជាលទ្ធផលក្នុង៩ខែ ឆ្នាំ២០២២ អង្គភាពទាំងពីរបានអនុវត្ត និងទទួលបានវឌ្ឍនភាពដូចមានក្នុងរបាយការណ៍ខាងក្រោម÷

- រៀបចំកម្រងទិន្នន័យស្តីពីចំណូលចរន្តថវិការដ្ឋ និងការប្រៀ បធៀបចំណូល-ចំណាយនឹងប្រទេសជិតខាង
- រៀបចំធ្វើបច្ចុ ប្បន្នភាពលើបទបង្ហាញចុងក្រោយនៃការសិក្សាដំណាក់កាលទី១ លើការវាយតម្លៃប្រព័ន្ធពន្ធលើប្រាក់ ចំណូលរូបវន្តបុគ្គលនៅកម្ពុជា
- រៀបចំការសិក្សាស្តីពីរចនាសម្ព័ន្ធនៃចំណូលតាមប្រភេទពន្ធតាមបណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍
- រៀបចំឯកសារទស្សនាទានស្តីពីការសិក្សាអំពីផលប៉ះពាល់នៃការកើនឡើងថ្លៃជី ចំណីសត្វ និងប្រេង លើវិស័យកសិកម្ម និងអាហារមូលដ្ឋាន
- រៀបចំចូលរួមរៀបចំកម្មវិធីShowcase Event ដែលជាកម្មវិធីមួយនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ាន
- រៀបចំកែសម្រួលកម្រងសំណួរសម្រាប់ការស្ទង់មតិជាមួយវិស័យឯកជន សម្រាប់ដំណើរការក្របខ័ណ្ឌវាយតម្លៃពាក់កណ្តាលអាណត្តិយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ លើការអនុវត្តគោលនយោបាយសារពើពន្ធ និងផ្នែកទំនើបភាវូបនីយកម្មរដ្ឋបាលពន្ធគយ



ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាសទី២ ឆ្នាំ២០២២

[1] មាត្រា ១២ នៃអនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- រៀបចំឯកសារទស្សនាទាន សម្រាប់រៀបចំសិក្ខាសាលាពិគ្រោះយោបល់ប្រចាំឆ្នាំវិស័យអាទិភាពទាំង៤
- រៀបចំក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការតម្រង់ទិសអាទិភាពគោលនយោបាយ និងពង្រឹងកិច្ចអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចកម្ពុជា ក្នុងគន្លងនៃប្រក្រតីភាពថ្មីឆ្នាំ២០២៣ និងឆ្នាំបន្ទាប់
- រៀបចំកម្រងទិន្នន័យហិរញ្ញវត្ថុសាធារណៈ ដើម្បីរៀបចំ Super Table
- រៀបចំកម្រងទិន្នន័យអំពី ការប្រមូលចំណូលចរន្តដល់ក្រុមការងារមូលនិធិរូបិយវត្ថុអន្តរជាតិ
- រៀបចំតាមដាន និងវិភាគជាប្រចាំលើការវិវឌ្ឍ និងស្ថានភាពនៃការប្រមូលចំណូល និងការអនុវត្តចំណាយ
- រៀបចំរៀបចំកម្រងចម្លើយឆ្លើយតបទៅនឹងការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ច អាស៊ានបូកបី
- រៀបចំសេចក្តីព្រាងបឋមក្របខណ្ឌគោលនយោបាយសម្រាប់ត្រៀមអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គលត្រឹមកម្រិតក្រុមបច្ចេកទេស
- រៀបចំសេចក្តីព្រាងនៃកម្រងសំណួរសម្រាប់ស្ទង់មតិវិស័យឯកជន ដែលជាអ្នកទទួលសេវាអ្នកជាប់ពន្ធសម្រាប់វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តសេវាអ្នកជាប់ពន្ធក្នុងក្របខណ្ឌយុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣

ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា

- រៀបចំសម្ភាសជាមួយភាគីពាក់ព័ន្ធនិងចងក្រងទិន្នន័យ ដើម្បីធ្វើការវាយតម្លៃ និងព្យាករម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំ២០២២ ដោយផ្តោតលើវិស័យកសិកម្ម
- រៀបចំទម្រង់ស្នើសុំទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវលើឧស្សាហកម្មផលិតស៊ីម៉ង់ត៍ និងអាករពិសេសលើផលិតផលស៊ីម៉ង់ត៍
- រៀបចំបូកសរុបទិន្នន័យពីវិស័យឯកជនពាក់ព័ន្ធ សម្រាប់ការសិក្សាស្រាវជ្រាវលើឧស្សាហកម្មផលិតស៊ីម៉ង់ត៍ និងអាករពិសេសលើផលិតផលស៊ីម៉ង់ត៍
- រៀបចំតារាងទិន្នន័យ Super table និងកម្រងតារាងទិន្នន័យស្តីពីម៉ាក្រូសេដ្ឋកិច្ចសម្រាប់វេទិកាសាធារណៈតាមអនឡាញស្តីពី "ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និង ច្បាប់ថវិកាឆ្នាំ២០២២"
- រៀបចំពិនិត្យនិងកែសម្រួលរបាយការណ៍ស្តីពីកិច្ចប្រជុំបច្ចេកទេសការទូទាត់ថវិកាលើកទី៣
- រៀបចំ ពិនិត្យមើលករណីសំណើសុំពិនិត្យនិងផ្តល់យោបល់លើសំណើសុំបោះផ្សាយសញ្ញាប័ណ្ណជាប្រាក់រៀលសម្រាប់វិយោគិនអន្តជាតិ នៅក្នុងទីផ្សារមូលបត្របំណុលក្រៅប្រទេស ដោយធនាគារអភិវឌ្ឍន៍អាស៊ី និងធ្វើលិខិតឆ្លើយតប

- រៀបចំលិខិត និងសេចក្តីព្រាងសេចក្តីសម្រេចស្តីពី "ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំមាគ៌ាវិនិយោគប្រកបដោយចីរភាព និងយុទ្ធសាស្ត្រហិរញ្ញប្បទាន"
- រៀបចំមតិយោបល់លើ "Draft Financial Gap Analysis of the Financing Strategy"
- រៀបចំគម្រោងទី១ ស្តីពី "ការវិភាគ និង វាយតម្លៃអំពីតំណភ្ជាប់ពាណិជ្ជកម្ម និង ផលិតភាពសេដ្ឋកិច្ចនៅកម្ពុជា" ដែលមានគោលបំណងដើម្បី ក. សិក្សា និងវាយតម្លៃអំពីឥទ្ធិពល និងផលប៉ះពាល់នៃយុទ្ធសាស្ត្រពាណិជ្ជកម្ម ដែលមានស្រាប់ទៅលើផលិតភាពសេដ្ឋកិច្ចនៅកម្ពុជា, ខ. កំណត់យុទ្ធសាស្ត្រជំរុញផលិតភាព ដើម្បីបង្កើនសមត្ថភាព និងលទ្ធភាពរបស់កម្ពុជាក្នុងការចាប់យក និងបង្កើនខ្សែច្រវាក់តម្លៃ និង គ. អភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់កែលម្អតំណភ្ជាប់រវាងពាណិជ្ជកម្ម និងផលិតភាពសេដ្ឋកិច្ច
- រៀបចំគម្រោងទី២ ស្តីពី "បច្ច័យនៃការរីកចម្រើននៃសេដ្ឋកិច្ចឌីជីថល ក្នុងការលើកកម្ពស់ និង ធ្វើបរិវត្តកម្មលើសមត្ថភាព និង លទ្ធភាពរបស់កម្ពុជា សម្រាប់ពង្រីកទំហំសេដ្ឋកិច្ច និងជំរុញពិពិធកម្មសេដ្ឋកិច្ច" ដែលមានគោលបំណងដើម្បី ក. ពិនិត្យ និងវិភាគអំពីទំនាក់ទំនងរវាងសេដ្ឋកិច្ចឌីជីថល ជាមួយផលិតភាពសេដ្ឋកិច្ច និងពិពិធកម្មសេដ្ឋកិច្ច និង ខ. អភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ពង្រឹងតំណភ្ជាប់រវាងផលិតភាពសេដ្ឋកិច្ច និងពិពិធកម្មសេដ្ឋកិច្ច
- បានបង្កើតក្រុមការងារត្រួតពិនិត្យក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា។

១.២. ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ ,អគ្គលេខាធិការដ្ឋានល្បែងពាណិជ្ជកម្មកម្ពុជា, និយ័តករធានារ៉ាប់រងកម្ពុជា, និយ័តករមូលបត្រកម្ពុជា, និយ័តករបរធនបាលកិច្ច,និយ័តករអាជីវកម្មអចលនទ្រព្យ និងបញ្ចាំ អង្គភាពសវនកម្ម នៃអាជ្ញាធរសេវាហិរញ្ញវត្ថុ មិនមែនធនាគារ ដែលទើបបង្កើត និងបំបែកចេញពីអគ្គនាយកឧស្សាហកម្មហិរញ្ញវត្ថុ និយ័តករគណនេយ្យ និងសវនកម្ម លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ អង្គភាពដែលទើបបំបែកពីឧស្សាហកម្មហិរញ្ញវត្ថុ មានមុខងារក្នុងការគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ អាជីវកម្មភ្នាល់គ្រប់ប្រភេទ អាជីវកម្មអចលនទ្រព្យនិងចូលរួមប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។ និយ័តករគណនេយ្យ និងសវនកម្ម បំពេញបេសកកម្មគ្រប់គ្រងអភិវឌ្ឍវិស័យគណនេយ្យនិងសវនកម្ម។ សម្រាប់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមវិញ បំពេញមុខងារជាសេនាធិការគោលនយោបាយ និងបច្ចេកទេសរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ ជាលទ្ធផល អង្គភាពអស់ខាងលើបានអនុវត្តនិងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

១.២.១. វិស័យល្បែងពាណិជ្ជកម្ម

- គិតត្រឹមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ ប្រតិបត្តិករកាស៊ីណូចំនួន ៧៩ បានបើកដំណើរការអាជីវកម្មក្នុងនោះមានប្រតិបត្តិករកាស៊ីណូចំនួន ៥១ក្រុមហ៊ុនបានបំពេញចំណូលកាតព្វកិច្ចពីល្បែងប្រចាំខែរួចរាល់ និងប្រតិបត្តិករកាស៊ីណូចំនួន ២៨ក្រុមហ៊ុន នៅមិនទាន់បានដាក់លិខិតប្រកាសចំណូលកាតព្វកិច្ចពីល្បែងប្រចាំខែ
- បានចុះត្រួតពិនិត្យ និងធ្វើសវនកម្មដល់ទីកន្លែងលើប្រតិបត្តិការកាស៊ីណូឆ្នាំ២០២១ តាមតំបន់ព្រំដែនកម្ពុជា-ថៃ, តំបន់ព្រំដែនកម្ពុជា-វៀតណាម, និងតំបន់ជាប់មាត់សមុទ្រ ដែលមិនទាន់ផ្តល់របាយការណ៍សវនកម្មឆ្នាំ២០២១ 6
- បានចេញសេចក្តីណែនាំដល់ប្រតិបត្តិករកាស៊ីណូទាំងអស់ឱ្យរៀបចំស្តង់ដាត្រួតពិនិត្យផ្ទៃក្នុង
- បានរៀបចំលិខិតស្តីពីការបង់កម្រៃសិទ្ធិផ្តាច់មុខប្រចាំឆ្នាំ២០២១ របស់ក្រុមហ៊ុនមួយចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២

- គិតត្រឹមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ មានប្រតិបត្តិករល្បែងផ្សងសំណាងចំនួន២៤ក្រុមហ៊ុនបានដាក់ពាក្យស្នើសុំអាជ្ញាបណ្ណក្នុងឆ្នាំ២០២២ ក្នុងនោះមានក្រុមហ៊ុនចំនួន១៨ បានបើកដំណើរការ និងក្រុមហ៊ុនចំនួន៣ មិនទាន់បើកដំណើរការ និង៣ក្រុមហ៊ុនទៀតបានស្នើសុំបិទអាជីវកម្មទៅវិញ
- គិតត្រឹមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ បានពិនិត្យលើស្តង់ដាត្រួតពិនិត្យផ្ទៃក្នុងរបស់ប្រតិបត្តិករល្បែងផ្សងសំណាងចំនួន១៨ក្រុមហ៊ុន
- បានចុះត្រួតពិនិត្យដល់ទីកន្លែងលើកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍សវនកម្មឯករាជ្យប្រចាំឆ្នាំ២០២១ របស់ប្រតិ- បត្តិករល្បែងផ្សងសំណាងចំនួន ១៧ក្រុមហ៊ុន
- បាន និងកំពុងធ្វើសវនកម្មនៅនឹងកន្លែងលើក្រុមហ៊ុនល្បែងផ្សងសំណាងចំនួន ២ក្រុមហ៊ុនបន្ថែមទៀតសរុបចំនួន ១៧ក្រុមហ៊ុន
- បានរៀបចំលិខិតដកប្រាក់តម្កល់ធានាអាជីវកម្មសរុបចំនួន១៣ក្រុមហ៊ុន ក្នុងនោះមានក្រុមហ៊ុនកាស៊ីណូចំនួន១១ និងក្រុមហ៊ុនល្បែងផ្សងសំណាងចំនួន២
- កាស៊ីណូចំនួន១៩ បានដាក់ពាក្យស្នើសុំចុះបញ្ជីប្រភេទល្បែង វិធានល្បែង ឧបករណ៍និងឬកម្មវិធីល្បែង
- ក្រុមហ៊ុនល្បែងផ្សងសំណាងចំនួន ១៥ បានដាក់ពាក្យស្នើសុំចុះបញ្ជីប្រភេទល្បែង និងឧបករណ៍ល្បែងសម្រាប់ល្បែងផ្សងសំណាង។ ក្នុងនោះបានពិនិត្យ និងវាយតម្លៃរួចរាល់លើពាក្យស្នើសុំចំនួន ០៥ ក្រុមហ៊ុន
- ចុះត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌអាជ្ញាបណ្ណកាស៊ីណូ និងអនុលោមភាពបច្ចេកទេសល្បែង តំបន់ខេត្តជាប់មាត់សមុទ្រ(ខេត្តព្រះសីហនុ) បានចំនួន ១២កាស៊ីណូ។

១.២.២. វិស័យបរធនបាលកិច្ច

- បានចេញវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចពាណិជ្ជកម្មចំនួន ៣៣
- រៀបចំប្រកាសស្តីពីការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃនៅក្នុងវិស័យបរធនបាលកិច្ច
- រៀបចំបង្កើតក្រុមការងារអភិវឌ្ឍប្រព័ន្ធ ចុះបញ្ជីបរធនបាលកិច្ច
- បានចុះអធិការកិច្ចបរធនបាលកិច្ច ហិរញ្ញវត្ថុ ស្ថាបនាសហគមន៍កម្ពុជា ចំនួន ១លើក
- ដាក់ឱ្យអនុវត្តប្រកាសស្តីពីសេវានៃការចុះបញ្ជីបរធនបាលកិច្ច
- រៀបចំគោលការណ៍ណែនាំស្តីពីវិធានប្រតិបត្តិការបរធនបាល
- រៀបចំគោលការណ៍ណែនាំស្តីពីការចុះត្រួតពិនិត្យដល់ទីកន្លែងប្រតិបត្តិការរបស់បរធនបាល
- រៀបចំប្រកាសស្តីពីការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យបរធនបាលកិច្ច
- រៀបចំប្រកាសស្តីពីការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃនៅក្នុងវិស័យបរធនបាលកិច្ច។

១.២.៣. វិស័យធានារ៉ាប់រងនៅកម្ពុជា

- គ្រប់គ្រងការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង និងសោធនឯកជន និងកិច្ចការគតិយុត្តិ
  - បានសម្រេចផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រងចំនួន២
  - បានសម្រេចផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន៨
  - បានសម្រេចបន្តសុពលភាពអាជ្ញាបណ្ណ÷ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន២, ក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន៣, ខ្នាតតូចចំនួន២, ភ្នាក់ងារធានារ៉ាប់រងចំនួន ៣, ជើងសាធានារ៉ាប់រងចំនួន១២, និងក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងចំនួន ២

- ត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រង
    - បានសម្រេចអនុញ្ញាតករណីស្នើសុំអនុញ្ញាតចុះកិច្ចសន្យាព្រមព្រៀងធានារ៉ាប់រងបន្តឆ្នាំ២០២២ ជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន៩
    - បានសម្រេចអនុញ្ញាតលើករណីស្នើសុំបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន២៦
    - បានសម្រេចលើការសុំអនុម័តលើការបង្កើនដើមទុនចុះបញ្ជីចំនួន១៥
    - បានសម្រេចមិនអនុញ្ញាតករណីស្នើសុំទិន្នន័យស្តីពីសមតុល្យគណនីនៃប្រាក់តម្កល់តាមច្បាប់របស់ក្រុមហ៊ុនចំនួន៩
    - បានសម្រេចអនុញ្ញាតករណីស្នើសុំធ្វើការវិនិយោគលើមូលបត្របំណុលរបស់ក្រុមហ៊ុនចំនួន២
    - បានសម្រេចអនុញ្ញាតករណីស្នើសុំការបញ្ជាក់ពីនិយ័តករធានារ៉ាប់រងកម្ពុជាអំពីបច្ចុប្បន្នភាព នៃការកំណត់ពី ចំណាត់ថ្នាក់អប្បបរមារបស់ក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេស និងការទទួលស្គាល់ក្រុមហ៊ុននិង/ឬភ្នាក់ងារចាត់ថ្នាក់ផ្សេងៗ ចំនួន ១

កម្មវិធីចែករំលែកចំណេះដឹងធានារ៉ាប់រងលេខ ០២២.១០

    - បានសម្រេចមិនអនុញ្ញាតលើសំណើសុំការអនុម័តលើកិច្ចសន្យាធានារ៉ាប់រងបន្តសម្រាប់ឆ្នាំ២០២២ ចំនួន ១
    - បានសម្រេចអនុញ្ញាតលើសំណើសុំវិនិយោគក្នុងមូលបត្ររដ្ឋរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន១
    - បានសម្រេចលើសំណើសុំអនុញ្ញាតលើការបើកសាខាក្នុងស្រុកចំនួន ១
    - បានសម្រេចលើករណីជូនដំណឹងស្តីពីការផាកពិន័យលើការមិនមាននាយកឯករាជ្យគ្រប់គ្រាន់អនុលោមតាមខ្លឹមសារប្រកាសស្តីពីអភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រងប្រការ៧ ចំនួន ១។

១.២.៤. វិស័យអចលនទ្រព្យ និងបញ្ចាំ

- ការផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍÷
    - ការផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍ចំនួន ០៤ ក្រុមហ៊ុន
    - លទ្ធផលចុះត្រួតពិនិត្យទីតាំង អាជីវកម្មដីឡូត៍ ចំនួន ០៤ ក្រុមហ៊ុន
- ការផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិ សម្រាប់រយៈពេល ០៩ខែ ឆ្នាំ២០២២÷
    - ផ្តល់អាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាននិងអគារសហកម្មសិទ្ធិជូន គម្រោងថ្មីចំនួន ៤៤គម្រោង, គម្រោងជាដំណាក់កាលចំនួន ២គម្រោង និងបន្តសុពលភាពអាជ្ញាបណ្ណចំនួន ៩គម្រោង និងផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ចំនួន ៧គម្រោង

- ចុះពិនិត្យដល់ទីតាំងសម្រាប់គម្រោងថ្មីចំនួន ១៧គម្រោង និងអនុញ្ញាតឱ្យក្រុមហ៊ុនដកប្រាក់តម្កល់ចំនួន ១៩ គម្រោង បង្វែរប្រាក់តម្កល់ចំនួន ២គម្រោង និងកែសម្រួលប្រាក់តម្កល់ចំនួន ១គម្រោង

- ការផ្តល់អាជ្ញាបណ្ណនិងវិញ្ញាបនបត្រវិជ្ជាជីវៈក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងអចលនវត្ថុ និងការផ្លាស់ប្តូរផ្សេងៗ សម្រាប់រយៈពេល ០៩ខែ ឆ្នាំ២០២២÷

សិក្ខាសាលាស្តីពីការលើកកម្ពស់ការយល់ដឹង និងបង្កើនប្រសិទ្ធភាពការអនុវត្តបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធនឹង អាជីវកម្មអភិវឌ្ឍអចលនវត្ថុ
ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២២

  - ផ្តល់អាជ្ញាបណ្ណ និង វិញ្ញាបត្រវិជ្ជាជីវៈជូនក្រុមហ៊ុនថ្មីចំនួន ៣២ក្រុមហ៊ុន
  - បន្តសុពលភាព/បង់ប្រចាំឆ្នាំ អាជ្ញាបណ្ណ និង/ឬវិញ្ញាបនបត្រវិជ្ជាជីវៈជូនក្រុមហ៊ុនចំនួន ១៧១ក្រុមហ៊ុន
  - អនុញ្ញាតបន្ថែមនិង/ឬផ្លាស់ប្តូរ/និងឬបញ្ឈប់អាជ្ញាបណ្ណ និង/ឬ វិញ្ញាបនបត្រវិជ្ជាជីវៈជូន ក្រុមហ៊ុនចំនួន ២៩ ក្រុមហ៊ុន
  - អនុញ្ញាតឱ្យផ្លាស់ប្តូរភាគហ៊ុននិកនិង/ឬសមាជិកក្រុមប្រឹក្សាភិបាល,ផ្លាស់ប្តូរទីតាំងជូនក្រុមហ៊ុនសរុបចំនួន ១៥ក្រុមហ៊ុន

- ការផ្តល់/បន្តអាជ្ញាបណ្ណអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
  - បានផ្តល់អាជ្ញាបណ្ណថ្មីតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាពត៌មានវិទ្យា ចំនួន៣៣ ក្រុមហ៊ុន/សហគ្រាស
  - បន្តសុពលភាពអាជ្ញាបណ្ណចំនួន ៣៤៤ ក្រុមហ៊ុន/សហគ្រាស
  - ចេញលិខិតគោលការណ៍ឯកភាពដកប្រាក់តម្កល់ និងបិទសកម្មភាពអាជីវកម្មចំនួន ១១ក្រុមហ៊ុន/សហគ្រាស
- ស្រាវជ្រាវអាជីវកម្មសេវាកម្មវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុ
  - ពិនិត្យរបាយការណ៍ក្រុមហ៊ុនចំនួន ១៥០ក្រុមហ៊ុន
  - ស្រាវជ្រាវអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ គ្មានអាជ្ញាបណ្ណ ០៣ក្រុមហ៊ុន
- អាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
  - ពិនិត្យរបាយការណ៍ក្រុមហ៊ុនចំនួន ៤០២ក្រុមហ៊ុន
  - ចុះត្រួតពិនិត្យអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទានចំនួន ១៨ ក្រុមហ៊ុន។

១.២.៥. វិស័យមូលបត្រកម្ពុជា

- ការគ្រប់គ្រង ត្រួតពិនិត្យ និងតាមដានអន្តរការីមូលបត្រ និងធ្វើពិពិធកម្មអន្តរការីមូលបត្រ

- បានចុះត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនអន្តរការីចំនួន ១៥ក្រុមហ៊ុន
- បានបញ្ចប់របាយការណ៍ស្តីពីលទ្ធផលចុះត្រួតពិនិត្យដល់ទីកន្លែងចំនួន ២២ករណី
- បានបញ្ចប់របាយការណ៍លទ្ធផលកិច្ចប្រជុំលើលទ្ធផលនៃការចុះត្រួតពិនិត្យដល់ទីកន្លែងចំ នួន ៤ករណី
- បានចេញលិខិតផ្តល់អនុសាសន៍លើលទ្ធផលនៃការចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុនចំនួន ៤ករណី

- ការគ្រប់គ្រង ត្រួតពិនិត្យ និងតាមដានទីផ្សារមូលបត្រ និងជំរុញការធ្វើពិពិធកម្មទីផ្សារមូលបត្រ
  - បានផ្តល់លេខអត្តសញ្ញាណវិនិយោគិនចំនួន ២ ៣៨៧
  - បានបន្តសុពលភាពលេខអត្តសញ្ញាណវិនិយោគិនចំនួន ៨៣៥
  - បានធ្វើបច្ចុប្បន្នភាពព័ត៌មានលេខអត្តសញ្ញាណវិនិយោគិនចំនួន ១៥៣

- គ្រប់គ្រង ត្រួតពិនិត្យការបោះផ្សាយលក់មូលបត្រ ធ្វើពិពិធកម្មផលិតផលមូលបត្រ និងតាមដានត្រួតពិនិត្យបុគ្គលបោះផ្សាយលក់មូលបត្រ
  - បានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍ប្រតិបត្តិការ និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំ២០២១ របស់ក្រុមហ៊ុនវាយតម្លៃចំនួន ៣ក្រុមហ៊ុន និងភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុលចំនួន ១ក្រុមហ៊ុន
  - បានពិនិត្យ និងវិភាគលទ្ធផលហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ និងប្រចាំឆ្នាំ២០២១ ចំនួន ១៣ ក្រុមហ៊ុន
  - បានពិនិត្យ និងវិភាគលទ្ធផលហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២២ ចំនួន ១៤ក្រុមហ៊ុន ត្រីមាសទី២ ឆ្នាំ ២០២២ ចំនួន ៧ក្រុមហ៊ុន និងត្រីមាសទី៣ ឆ្នាំ២០២២ ចំនួន ១ ក្រុមហ៊ុន
  - បានរៀបចំលិខិតស្តីពីកំហុសឆ្គងលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២១ និងត្រីមាសទី១ ឆ្នាំ ២០២២ របស់បុគ្គលចុះបញ្ជីលក់មូលបត្រ ចំនួន ២ ករណី
  - បានតាមដាន និងត្រួតពិនិត្យលើការអនុវត្តកាតព្វកិច្ចនៃការផ្តល់របាយការណ៍សាមាយិក (របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០២១,របាយការណ៍ប្រចាំឆ្នាំ២០២១,របាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២២, និងរបាយការណ៍ប្រចាំត្រីមាសទី២ ឆ្នាំ២០២២) ចំនួន ៥៨ ករណី។

១.៣. ការងារគាំពារសង្គម

- បានចុះពិនិត្យ និងសង្កេតការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូន ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

- បានចុះពិនិត្យ និងសង្កេតការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដោយផ្តោតលើក្រុមគោលដៅជនចាស់
- បានសិក្សាពីជម្រើសក្នុងការកែសម្រួលជំពូកពាក់ព័ន្ធនឹងទោសប្បញ្ញត្តិក្នុងសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធគាំពារសង្គម

ការបើកប្រាក់ឧបត្ថម្ភបន្ថែមជូនកម្មករនិយោជិតជាស្ត្រីនៅពេល

- បានរៀបចំសេចក្តីព្រាងឯកសារទស្សនទានស្តីពីសេចក្តីព្រាងច្បាប់ ស្តីពីប្រព័ន្ធគាំពារសង្គម
- បានរៀបចំរបាយការណ៍ ស្តីពីការរៀបចំសេចក្តីព្រាងក្របខណ្ឌបទបញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធជំនួយសង្គម
- បានធ្វើការស្រាវជ្រាវរៀបចំសេចក្តីព្រាងក្របខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រព័ន្ធជំនួយសង្គម
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយយន្តការនៃការដោះស្រាយវិវាទក្នុងប្រព័ន្ធគាំពារសង្គម
- បានសិក្សាស្រាវជ្រាវបទប្បញ្ញត្តិមួយចំនួនជាធាតុចូលបន្ថែម ដើម្បីកែសម្រួលខ្លឹមសារពាក់ព័ន្ធទៅលើ សេចក្តីព្រាងប្រកាសស្តីពីការដោះស្រាយវិវាទក្នុងប្រព័ន្ធសន្តិសុខសង្គម
- បានពិនិត្យរបាយការណ៍បឋមលើឯកសារទស្សនទាននិមាបនកម្មគតិយុត្ត ក្នុងប្រព័ន្ធគាំពារសង្គមរបស់ទីប្រឹក្សាជាន់-ខ្ពស់ ចំនួន ១៤ ឯកសារ
- បានចុះធ្វើសវនកម្មកម្មវិធី លើកម្មវិធីការផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលសម្រាប់ស្ត្រីសម្រាលកូនរបស់កម្មករនិយោជិតក្នុង និងក្រៅប្រព័ន្ធ នៅប.ស.ស. និងក្រសួងសុខាភិបាល
- បានព្រាងឯកសារទស្សនទានបច្ចេកទេស ស្តីពីការអភិវឌ្ឍមុខងារសមកាលកម្មទិន្នន័យដោយស្វ័យប្រវត្តិសម្រាប់ប្រព័ន្ធយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ជាមួយប្រព័ន្ធ PMRSនៃទីភ្នាក់ងារបញ្ជាក់ចំណាយ សេវាសុខាភិបាល។

១.៤. ការងារគណនេយ្យ និងសវនកម្ម

- បានប្រមូលចំណូលពីកម្រៃសេវាដាក់របាយការណ៍ហិរញ្ញវត្ថុដែលរងសវនកម្មសម្រាប់ឆ្នាំ២០២០-២០២១តាមរយៈប្រព័ន្ធ e-filling និងចំណូលផ្សេងៗដែលជាប្រភពធនធានរបស់ ននិយ័តករគណនេយ្យ និងសវនកម្ម សម្រាប់ខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២
- ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញត្រូវបានរៀបចំរួចរាល់និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការដំណាក់កាលទី១
- បានរៀបចំរួចរាល់នូវសេចក្តីព្រាងប្រកាសស្តីពីការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល កម្រិតជំនាញ
- សេចក្តីព្រាងស្តង់ដាគណនេយ្យសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាលកំពុងត្រូវបានរៀបចំកម្រិតបច្ចេកទេស

- ឯកសារសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ ត្រូវបានអនុម័តជាផ្លូវការដោយរាជរដ្ឋាភិបាល
- ប្រកាសដែលតម្រូវឱ្យមានការលាតត្រដាងកំណត់សម្គាល់ និងការទទួលស្គាល់គណនីត្រូវទទួល និងគណនីត្រូវសង នៃប្រតិបត្តិការអនុវត្តកាតព្វកិច្ច នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ កំពុងត្រូវបានរៀបចំក្នុងកម្រិតបច្ចេកទេស
- ទទួល និងត្រួតពិនិត្យការស្នើសុំលេខអត្តសញ្ញាណកម្មរាយការណ៍របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសរងសវនកម្មឯករាជ្យចំនួន១,០៤៦សហគ្រាសមិនរងសវនកម្មឯករាជ្យចំនួន១២,២៧៩ និងអង្គភាពមិនស្វែងរកប្រាក់ចំណេញចំនួន ៩១៨
- បានរៀបចំលិខិតពិន័យអន្តរការណ៍ទៅសហគ្រាសដែលមិនបានដាក់ ឬយឺតការដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទឆ្នាំ២០២០ ចំនួន៣១៥
- ការចុះត្រួតពិនិត្យកាតព្វកិច្ចគណនេយ្យនិងសវនកម្មសហគ្រាសសម្រាប់ការិយបរិច្ឆេទគណនេយ្យ ឆ្នាំ២០២០ ចំនួន៥៥
- បានបើកប្រព័ន្ធដាក់របាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសរងសវនកម្មឯករាជ្យចំនួន១៦៧ និងសហគ្រាសមិនរងសវនកម្មឯករាជ្យចំនួន ១៣៩
- ពិនិត្យនិងផ្ទៀងផ្ទាត់បញ្ជីឈ្មោះសហគ្រាស ដែលបង់កម្រៃសេវាទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយ-បរិច្ឆេទគណនេយ្យ២០២០ ចំនួន ៤៣
- រៀបចំលិខិតការរំលឹកការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មសម្រាប់ការិយច្ឆេទឆ្នាំ២០២១ ចំនួនចំនួន ៥៨
- បានរៀបចំលិខិតពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹង ច្បាប់ស្តីពីគណនេយ្យនិងសវនកម្មសម្រាប់សហគ្រាសចំនួន៨
- ទទួលលិខិតពន្យារពេលរបស់អង្គភាពមិនស្វែងរកប្រាក់ចំណេញចំនួន៦ ក្នុងការបញ្ចប់ការងារធ្វើសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មសម្រាប់ឆ្នាំ២០២១
- បានរៀបចំលិខិតពិន័យដល់សហគ្រាសរងសវនកម្មឯករាជ្យ សម្រាប់ការដាក់បញ្ជូនរបាយការណ៍យឺតមកនិយ័តករគណនេយ្យ និងសវនកម្ម មានចំនួន៥
- បានទទួលរបាយការណ៍ហិរញ្ញវត្ថុសម្រាប់សហគ្រាសរងសវនកម្មឯករាជ្យចំនួន១,៣៨១ និងអង្គភាពមិនស្វែងរក-ប្រាក់ចំណេញ ចំនួន៤០៩។

២. ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ

គោលបំណងគោលនយោបាយទី២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺ "ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ" ដែលមានកម្មវិធីចំនួន៣។ លទ្ធផលនៃការអនុវត្តក្នុង៩ខែ ឆ្នាំ២០២២ នៃការអនុវត្តនៃគោលបំណងគោលនយោបាយទី២ នេះ មានដូចក្នុងរបាយការណ៍ខាងក្រោមនេះ÷

២.១. ការកៀរគរចំណូលថវិកាជាតិ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានបេសកកម្មសំខាន់ៗក្នុងនោះ÷ ១.ទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងប្រមូលអាករ និងកម្រៃផ្សេងៗលើទំនិញនាំចេញ ឬនាំចូល ស្របតាមបញ្ញត្តិ ស្តីពីគយ ព្រមទាំងច្បាប់ និងបទបញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងការនាំចេញ នាំចូល ការធ្វើចរាចរ និងការធ្វើសន្និធិទំនិញ ២.ដាក់បទបញ្ញត្តិលើការធ្វើចរាចរ ការធ្វើសន្និធិ និងការដឹកជញ្ជូនឆ្លងកាត់នៃទំនិញនាំ

ចេញ ឬនាំចូល ៣. ជំរុញការបង្ការ និងបង្ក្រាបអំពើល្មើស និងអំពើរត់ពន្ធ ៤.ចូលរួមអនុវត្តគោលនយោបាយពាណិជ្ជកម្មអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ៥. ជំរុញអនុវត្តតាមស្តង់ដារអន្តរជាតិ និងឧត្តមានុវត្តន៍ ដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យគយ និងការសម្រួលពាណិជ្ជកម្ម ជាពិសេស ការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ និងការធ្វើស្វ័យប្រវត្តិកម្មគយ[2]។ ដោយឡែកអគ្គនាយកដ្ឋានពន្ធដារ មានបេសកកម្មសំខាន់ៗ ក្នុងនោះ ១. ផ្តល់សេវាដល់អ្នកជាប់ពន្ធរួមមានការផ្តល់ព័ត៌មាន អប់រំ ពន្យល់ណែនាំ ដើម្បីឱ្យអ្នកជាប់ពន្ធប្រតិបត្តិត្រឹមត្រូវ តាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ២. អនុវត្តកម្មវិធីចាប់បង្ខំ ដោយធ្វើសវនកម្ម ការអនុវត្តវិធានការតឹងទារ អនុវត្តទោសទណ្ឌ តាមការកំណត់ស្តីពីពន្ធដារ ចំពោះអ្នកជាប់ពន្ធដែលមិនបានប្រតិបត្តិត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ៣. ប្រមូលចំណូលពន្ធ តាមការអនុវត្តត្រឹមត្រូវនូវច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ និងបង់គ្រប់គ្រាន់ចូលថវិកាជាតិ ៤. ផ្តល់សេវា និងការអប់រំអ្នកជាប់ពន្ធ ដើម្បីធានាឱ្យច្បាប់នានាស្តីពីពន្ធដារ ត្រូវបានគោរព និងអនុវត្តត្រឹមត្រូវ ៥. អនុវត្តកម្មវិធីចាប់បង្ខំ ប្រកបដោយប្រសិទ្ធភាព មានការទទួលខុសត្រូវខ្ពស់ និងស្មើភាពគ្នា ចំពោះអ្នកជាប់ពន្ធ ដែលមិនគោរពច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ ៦. អនុវត្តគោលការណ៍យុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្ត ចំពោះរដ្ឋបាលសារពើពន្ធ ៧. បន្ថយការចំណាយរបស់រដ្ឋបាលសារពើ-ពន្ធ ក្នុងការរៀបចំកម្មវិធី និងកិច្ចដំណើរការរបស់ក្រសួង ធ្វើឱ្យមានភាពសាមញ្ញ ចំពោះតម្រូវការផ្សេងៗ និងបន្ថយចំណាយរបស់អ្នកជាប់ពន្ធ ៨.បង្កើនសមត្ថភាព ចំណេះដឹងដល់មន្ត្រីពន្ធដារជាប្រចាំ ដើម្បីបំពេញការងារឱ្យមានប្រសិទ្ធភាព ៩.បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង តាមរយៈគោលនយោបាយ កិច្ចដំណើរការការងារ និងប្រព័ន្ធការងារ ដែលមានភាពច្បាស់លាស់ ទំនើប និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងាររបស់ខ្លួន[3]។ ផ្នែកនេះក៏ចូលរួមអនុវត្តដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ[4]។ ជាលទ្ធផល អគ្គនាយកដ្ឋានបានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

២.១.១. ការកៀរគរចំណូលសារពើពន្ធ

- ការគ្រប់គ្រងចំណូលពន្ធដារកម្ពុជា
    - សរុបរយៈពេល ៩ខែ ឆ្នាំ២០២២ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ១០ ៩០៨,១៩ ប៊ីលានរៀល (ប្រមាណជា ២ ៦៩៣,៣៨ លានដុល្លារ) ស្មើនឹង ៩៥,៥៣% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០២១ ឃើញថាកើនឡើងចំនួន ២ ៣៥១,០៧ ប៊ីលានរៀល (ប្រមាណជា ៥៨០,៥១ លានដុល្លារ) ស្មើនឹង ២៧,៥0%
    - សរុបរយៈពេល ៩ខែ ឆ្នាំ២០២២ នេះ ចំណូលពន្ធ-អាករទៅតាមប្រភេទពន្ធ និងតាមសកម្មភាពអាជីវកម្មសំខាន់ៗ ឃើញថាមានលម្អៀងធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ដូចមានរៀបរាប់ក្នុងតារាងខាងក្រោម÷

---

[2] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[3] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[4] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

តារាងចំណូលតាមប្រភេទពន្ធក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

ប្រភេទពន្ធសំខាន់ៗ	៩ខែ ឆ្នាំ២០២១	៩ខែ ឆ្នាំ២០២២	លម្អៀង		អត្រាកំណើន ឬថយចុះ
	ឯកតា ÷ ប៊ីលានរៀល		ប៊ីលានរៀល	លានដុល្លារ	
អាករលើតម្លៃបន្ថែម	១ ៧៩៣,៧២	២ ៤១៩,១៦	៦២៥,៤៤	១៥៤,៤៣	៣៤,៨៧%
ពន្ធលើប្រាក់ចំណូល	៣ ០៤៣,៥៩	៣ ៨៥០,៣៧	៨០៦,៧៧	១៩៩,២០	២៦,៥១%
អាករពិសេស	៦១៥,១១	៧៩៩,០២	១៧៩,៩០	៤៤,៤២	២៩,២៥%
ពន្ធលើប្រាក់បៀវត្ស	៦៨៣,០០	៨៤៧,៧២	១៦៤,៧២	៤០,៦៧	២៤,១២%
ពន្ធប្រថាប់ត្រា	៤៨៣,៨៧	៦៣៣,៣៨	១៤៩,៥១	៣៦,៩១	៣០,៩០%
ពន្ធលើឈ្នួលផ្ទះនិងដី	១៣,៥២	១៥,៨០	២,២៧	០,៥៦	១៦,៨៣%

តារាងចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

សកម្មភាពអាជីវកម្ម	៩ខែ ឆ្នាំ២០២១	៩ខែ ឆ្នាំ២០២២	លម្អៀង		អត្រាកំណើន ឬថយចុះ
	ឯកតា ÷ ប៊ីលានរៀល		ប៊ីលានរៀល	លានដុល្លារ	
នីហរ័ណ អាហរ័ណ (រួមបញ្ចូលការលក់ផលិតផលតេលសិលា)	១ ៧៥០,៦៣	១ ៦៧៦,៣៧	(៧៤,២៥)	(១៨,៣៣)	(៤,២៤%)
សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង	១ ៨៤៩,៤៧	២ ៣៩០,៨៣	៥៤១,៣៦	១៣៣,៦៧	២៩,២៧%
កសិកម្ម រុក្ខប្រមាញ់ និងនេសាទ	៣៦,១៧	៥៨,៧៨	២២,៦១	៥,៥៨	៦២,៥០%
ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ	៤៤,២៨	៤៤,៩៧	០,៦៩	០,១៧	១,៥៦%
កម្មន្តសាល	១ ៣០៩,៨៨	២ ២៩៩,៤២	៩៨៩,៥៣	២៤៤,៣៣	៧៥,៥៤%
សកម្មភាពអចលនវត្ថុ	៥៧៦,២៩	៧៤៤,៤៥	១៦៨,១៦	៤១,៥២	២៩,១៨%
ការដឹកជញ្ជូន និងការស្តុកទុក	៣៤៤,៨២	៤៥៨,៧៥	១១៣,៩២	២៨,១៣	៣៣,០៤%
ព័ត៌មានវិទ្យា និងទូរគមនាគមន៍	៤៩៥,១៤	៦០៩,៣២	១១៤,១៧	២៨,១៩	២៣,០៦%
ការអប់រំ	៤៦,៣៧	៦១,២៤	១៤,៨៧	៣,៦៧	៣២,០៧%
សេវាកម្មស្នាក់នៅ និងអាហារ	១០៨,៤៨	១៧២,៥៥	៦៤,០៦	១៥,៨២	៥៩,០៦%
ការសាងសង់	៤៤៥,១៣	៥២៦,១៣	៨០,៩៩	១៩,៩៩	១៨,២០%
ការផ្គត់ផ្គង់អគ្គិសនី ចំហាយទឹក និងខ្យល់ត្រជាក់	៣០៥,០៨	២៨៣,៣៦	(២១,៧២)	(៥,៣៦)	(៧,១២%)
សកម្មភាពវិជ្ជាជីវៈ វិទ្យាសាស្ត្រ និងបច្ចេកទេស	២៣៦,៩៥	៣៦៨,៨២	១៣១,៨៦	៣២,៥៦	៥៥,៦៥%
សកម្មភាពរដ្ឋបាលនិងគាំទ្រផ្សេងទៀត	៦៤,៧០	៩២,៨៩	២៨,១៩	៦,៩៦	៤៣,៥៧%
សកម្មភាពសេវាកម្មផ្សេងទៀត	៤៥,៣០	៥១,៤៦	៦,១៦	១,៥២	១៣,៦០%

- សរុបរយៈពេល ៩ខែ ឆ្នាំ២០២២ នេះ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលប្រមូលតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបែងចែកតាមប្រភេទអ្នកជាប់ពន្ធ ដូចខាងក្រោម÷
  - អ្នកជាប់ពន្ធធំ ចំនួន ៨ ៣០៥,៣៨ ប៊ីលានរៀល (ប្រមាណជា ២ ០៥០,៧១ លានដុល្លារ) ស្មើនឹង ៧៦,១៥% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ចំណូលតាមប្រភេទអ្នកជាប់ពន្ធធំកើនឡើងចំនួន ១ ៨១៩,៥១ ប៊ីលានរៀល (ប្រមាណជា ៤៤៩,២៦ លានដុល្លារ) ស្មើនឹង ២៨,០៥%
  - អ្នកជាប់ពន្ធមធ្យម ចំនួន១ ៦២៤,៦៣ ប៊ីលានរៀល(ប្រមាណជា ៤០១,១៤ លានដុល្លារ) ស្មើនឹង ១៤,៨៥% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ចំណូលតាមប្រភេទអ្នកជាប់ពន្ធមធ្យមកើនឡើងចំនួន ៣៥៨,៥៥ ប៊ីលានរៀល (ប្រមាណជា ៨៨,៥៣ លានដុល្លារ) ស្មើនឹង ២៨,៣២%
  - អ្នកជាប់ពន្ធតូច ចំនួន ៤៦,៩៨ ប៊ីលានរៀល (ប្រមាណជា ១១,៦០ លានដុល្លារ) ស្មើនឹង ០,៤៣% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២១ ចំណូលតាមប្រភេទអ្នកជាប់ពន្ធតូចកើនឡើងចំនួន១៣,១០ប៊ីលានរៀល(ប្រមាណជា ៣,២៣ លានដុល្លារ) ស្មើនឹង ៣៨,៦៧%
  - ផ្សេងៗ (ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន ៩៣១,២០ ប៊ីលានរៀល (ប្រមាណជា ២២៩,៩២ លានដុល្លារ) ស្មើនឹង ៨,៥៤% ធៀបនឹងចំណូលពន្ធ-អាករសរុប ហើយប្រៀបធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២១ចំណូលពន្ធផ្សេងៗកើនឡើងចំនួន១៨១,៦៧ប៊ីលានរៀល(ប្រមាណជា ៤៤,៨៥ លានដុល្លារ) ស្មើនឹង ២៤,២៤%
- ការចុះបញ្ជីពន្ធដារ÷សម្រាប់រយៈពេល ៩ខែ ឆ្នាំ២០២២ បានពិនិត្យនិងអនុម័តលើឯកសារស្នើសុំចុះបញ្ជីពន្ធដារចំនួន ៩ ៥៧៧ សហគ្រាស (ពន្ធធំ ៤៨១ ពន្ធមធ្យម ៤ ៧៨១ ពន្ធតូច ៤ ៣១៥) ដែលមានលម្អិតដូចខាងក្រោម÷
  - សហគ្រាសបានចុះបញ្ជីជោគជ័យចំនួន ៨ ៣២១ សហគ្រាស (ពន្ធធំ ៤៥៣ ពន្ធមធ្យម ៣ ៩៧៩ ពន្ធតូច ៣ ៨៨៩) ក្នុងនោះតាមថ្នាលចំនួន ៧ ៥០៨ សហគ្រាស (ពន្ធធំ ៣១០ ពន្ធមធ្យម ៣ ៥៧៥ ពន្ធតូច ៣ ៦២៣)
  - សហគ្រាសត្រូវបានកំណត់ថាមានហានិភ័យចំនួន ១ ២៥៦ សហគ្រាស (ពន្ធធំ ២៨ពន្ធមធ្យម ៨០២ ពន្ធតូច ៤២៦) ក្នុងនោះតាមថ្នាលចំនួន ១ ១៥០ សហគ្រាស (ពន្ធធំ ២៨ ពន្ធមធ្យម ៧១២ ពន្ធតូច ៤១០) ដោយបានបដិសេធការចុះបញ្ជីចំនួន ៣១៩ សហគ្រាស និងអនុម័តបញ្ជូនពិនិត្យបន្ថែមចំនួន ៩៣៧ សហគ្រាស។ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ២០២២ ឯកសារសល់យោងចុងគ្រាមានចំនួន ៤៧៤ សហគ្រាស ក្នុងនោះតាមថ្នាលចំនួន ២៩៣ សហគ្រាស
- លទ្ធផលការងារផ្នែកសវនកម្ម÷ សរុបរយៈពេល ៩ខែ ឆ្នាំ២០២២ នេះ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបានចំនួន ៨ ១១៤ ករណី មានប្រាក់ពន្ធចំនួន ៨ ៨៦៣,៦៥ ប៊ីលានរៀល (ប្រមាណជា ២ ១៨៨,៥៥ លានដុល្លារ)។ ប្រសិនបើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុង ឆ្នាំ២០២១ ឃើញថាការធ្វើសវនកម្មក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ គឺមានការកើនឡើងចំនួន ២ ៤៧៥ ករណី (ស្មើនឹង

៤៣,៩០%) និងមានប្រាក់ពន្ធកើនឡើង ចំនួន ២ ៧១៦,៨០ ប៊ីលានរៀល (ប្រមាណ ៦៧០,៨១ លានដុល្លារ) ស្មើនឹង ៤៤,២០%

- លទ្ធផលការងារគ្រប់គ្រងប្រមូលបំណុលពន្ធ ៖សរុបក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ បំណុលពន្ធប្រមូលបានមានចំនួន ៨៣៥ ២០៥ លានរៀល (ប្រមាណជា ២០៦,២២ លានដុល្លារ) បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ មានចំនួន ៧៣២ ៦២៤ លានរៀល គឺមានការកើនឡើងចំនួន ១០២ ៥៨១ លានរៀល (ប្រមាណជា ២៥,៣២ លានដុល្លារ) ស្មើនឹង ១៩,៥៨%

• ការគ្រប់គ្រងចំណូលគយ និងរដ្ឋាករកម្ពុជា

- ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ អគរ ប្រមូលចំណូលបានចំនួន ៨ ២៥៨,៧២ ប៊ីលានរៀល ឬ ២ ០២៦,៨២ លានដុល្លារអាមេរិកត្រូវជាប្រមាណ ៧៨,៧៩% នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ កើនឡើង ១ ៣៧៧,៣២ ប៊ីលានរៀល ឬ ៣៣៨,០៨ លានដុល្លារអាមេរិក ត្រូវជាប្រមាណ ២០,០២% បើប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១។ ទន្ទឹមនេះ តួលេខកត់ត្រាដោយរតនាគារជាតិមានចំនួន ៧ ៩៧៥,៣៨ ប៊ីលានរៀល ឬ ១ ៩៥៧,៤៦ លានដុល្លារអាមេរិក ត្រូវជា ៧៦,០៩% នៃផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២។ បើប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១ ចំណូលកត់ត្រាដោយរតនាគារជាតិក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ កើនឡើង ១ ៤៤៥,៤៧ ប៊ីលានរៀល ឬ ៣៥៤,៨១ លានដុល្លារអាមេរិក ត្រូវជា ២២,១៤%
- ចំណូលតាមប្រភេទពន្ធនិងអាករ

ក្រាហ្វិកប្រៀបធៀបចំណូលតាមប្រភេទពន្ធនិងអាករ ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២១ និងឆ្នាំ២០២២



ក្រាហ្វិកប្រៀបធៀបចំណូលតាមក្រុមទំនិញក្នុងរយៈពេល ៩ខែ ឆ្នាំ២០២១ និងឆ្នាំ២០២២



- ពន្ធនិងអាករជាបន្ទុករបស់រដ្ឋ ÷ ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋមានចំនួន ១០ ៦៧២,៤១ ប៊ីលានរៀល ឬ ២ ៦១៩,៦៨ លានដុល្លារអាមេរិក កើនឡើង ១ ៥៨៩,១៩ ប៊ីលានរៀល ឬ ៣៩០,០៩ លានដុល្លារអាមេរិក ត្រូវជាប្រមាណ ១៧,៥០% បើប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១។ ក្នុងនោះ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងវិស័យវិនិយោគកាត់ដេរចំនួន ៥ ១៤០,៨២ ប៊ីលានរៀល ត្រូវជាប្រមាណ ៤៨,១៧% នៃពន្ធនិងអាករជាបន្ទុករបស់រដ្ឋសរុប កើនឡើង ៣៩៧,៤៣ ប៊ីលានរៀល ឬ ៨,៣៨% ប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១។ ពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងវិស័យវិនិយោគមិនមែនកាត់ដេរចំនួន ៣ ៨៦៤,០៦ ប៊ីលានរៀល ត្រូវជាប្រមាណ ៣៦,២១% នៃពន្ធនិងអាករជាបន្ទុករបស់រដ្ឋសរុប កើនឡើង ៧០៩,៧៨ ប៊ីលានរៀល ឬ ២២,៥០% ប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១។ ទន្ទឹមនេះ មុខសញ្ញាផ្សេងទៀតដូចជា ក្រសួង-ស្ថាប័នរដ្ឋ អង្គការ ស្ថានទូត និងជំនួយបរទេសជាដើម មានចំនួន ១ ៦៦៧,៥៣ ប៊ីលានរៀល ត្រូវជាប្រមាណ ១៥,៦២% នៃពន្ធនិងអាករជាបន្ទុករបស់រដ្ឋសរុប កើនឡើង ៤៨១,៩៧ ប៊ីលានរៀល ឬ ៤០,៦៥% ប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១។ ជាការកត់សម្គាល់ ប្រាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋនេះ មានទំហំប្រមាណ ១២៩,២៣% នៃចំណូលពន្ធនិងអាករដែលប្រមូលបានក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២

ក្រាហ្វិកប្រៀបធៀបពន្ធនិងអាករជាបន្ទុករបស់រដ្ឋក្នុងរយៈពេល ៩ខែ ឆ្នាំ២០២១ និងឆ្នាំ២០២២



- ទំហំពាណិជ្ជកម្ម
  - ទំហំពាណិជ្ជកម្មនៃការនាំចូល÷ ទំហំពាណិជ្ជកម្មនៃការនាំចូលសរុបដោយមិនរាប់បញ្ចូលនូវការនាំចូលមាសបរទេសក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ មានតម្លៃសរុប ១៩ ៣៦៣,២៣ លានដុល្លារអាមេរិក កើនឡើង ២ ៨៣០,៨២ លានដុល្លារអាមេរិក ឬ ១៧,១២% បើប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១
  - ទំហំពាណិជ្ជកម្មនៃការនាំចេញ ÷ ទំហំពាណិជ្ជកម្មនៃការនាំចេញសរុបរយៈពេល ៩ខែ ឆ្នាំ២០២២ មានតម្លៃសរុប ១៧ ២២២,៥៥ លានដុល្លារអាមេរិក (មិនគិតមាសបរទេស) កើនឡើង ៣ ១៤៨,១៨ លានដុល្លារអាមេរិក ត្រូវជា ២២,៣៧%បើប្រៀបធៀបនឹង ៩ខែ ឆ្នាំ២០២១ ដែលមានតួលេខ ១៤ ០៧៤,៣៧ លានដុល្លារអាមេរិក
- ការបង្ក្រាបអំពើរត់គេចពន្ធ÷ ក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២ អគរ បានបង្ក្រាបបទល្មើសរត់គេចពន្ធចំនួន ២៣ ៣៨៥ ករណី រួមមាន ករណីធំ ៦៩៦ និងករណីតូច ២២ ៦៨៩។ បើប្រៀបធៀបនឹងរយៈពេល ៩ខែ ឆ្នាំ២០២១ ចំនួនករណីដែលបង្ក្រាបបានក្នុងរយៈពេល ៩ខែ ឆ្នាំ២០២២នេះ កើនឡើង ១១ ៧៥៣ ករណី ឬ ១០១,០៤%។ ទន្ទឹមនេះ អគរ បានដោះស្រាយកំណត់ហេតុបទល្មើសគយរួចចំនួន ២៣ ៣៩០ ករណី ដោយ

ប្រមូលបានប្រាក់ពន្ធអាករនិងពិន័យចំនួន ១១៧,២៧ ប៊ីលានរៀល។ មុខទំនិញល្មើសសំខាន់ៗដែលបង្ក្រាបបានរួមមាន÷ ផលិតផលគេលសិលា ១២៣ ២១៨ លីត្រ, រថយន្ត ៥៣២ គ្រឿង (ចង្កូតស្តាំ ២៧ គ្រឿង), ទោចក្រយានយន្ត ២២ ០២៨ គ្រឿង, ទូរស័ព្ទដៃស្មាតហ្វូន ៤១៧៥ គ្រឿង, ទូរទស្សន៍ថ្មី ៥៦៧ គ្រឿង, ម៉ាស៊ីនត្រជាក់ថ្មី ៨៣៥ គ្រឿង, ម៉ាស៊ីនបោកគក់សម្លៀកបំពាក់ថ្មី ៣១០ គ្រឿង, ទូទឹកកកថ្មី ៥៥៦ គ្រឿង, ម៉ាស៊ីនបន្សុទ្ធខ្យល់ថ្មី ១០ គ្រឿង, ម៉ាស៊ីនស្កែនអ្នកដំណើរនិងអីវ៉ាន់ថ្មី ១០ គ្រឿង, ម៉ាស៊ីនបូម ៣០ គ្រឿង, សម្ភារកុំព្យូទ័រថ្មី ១,៥៧៣ គ្រឿង, Speaker ២៤០ គ្រឿង, សម្ភារប្រើអគ្គិសនីចម្រុះផ្សេងទៀត ១០៤ គ្រឿង។ ស្រាបរទេសចម្រុះ ២ ១៤០ កេស, ស្រាបៀរ ២ ៨១៩ កេស, ភេសជ្ជៈចម្រុះ ៩ ៥៤៤ កេស, អាគុយថ្មី ២ ៦៧០ រាយ, គ្រឿងឧបភោគបរិភោគ ៣៣០,៦៦ តោន, សម្ភារសំណង់ ៥១៤,៥៧ តោន, ទំនិញផ្សេងទៀត ៨៣៣,៦៥ តោន, គ្រឿងញៀនចម្រុះ ៣៤ ១៨៦,៦៥ ក្រាម, និងរូបិយបណ្ណបរទេស ៧៤៨ ១០៦ ដុល្លារអាមេរិក។

២.១.២. ការគៀរគរចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ

- ការគ្រប់គ្រងប្រមូលចំណូលពីទ្រព្យសម្បត្តិរដ្ឋ
  - បានចុះបេសកកម្មទៅខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ចាម ដើម្បីចុះពិនិត្យសិក្សា និងវាយតម្លៃលើការដោះដូរទីតាំងដី
  - បានចុះបេសកកម្មទៅខេត្តស្វាយរៀង ដើម្បីចូលរួមប្រជុំចុះពិនិត្យ និងវាយតម្លៃការដោះដូរទីតាំងដី អគារប៉ុស្តិ៍នគរបាលច្រកព្រំដែនទ្វេភាគីបុសមន នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង ជាថ្នូរនឹងសំណង់អគារធ្វើការថ្មី ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ របស់ក្រុមហ៊ុន អូលែរ អ៊ីមផត អិចផត ឯ.ក
  - បានចុះបេសកកម្មទៅខេត្តក្រចេះ ចូលរួមចុះពិនិត្យនិងវាយតម្លៃដោះដូរទីតាំងនៅខេត្តក្រចេះ
  - បានចុះបេសកកម្មទៅខេត្តសៀមរាប ដើម្បីចូលរួមពិនិត្យសិក្សា និងវាយតម្លៃការស្នើសុំបញ្ចុះតម្លៃឈ្នួលទីតាំងសណ្ឋាគារ១កន្លែង ប្រចាំខែ ៥០%
  - បានរៀបចំយោបល់គោរពស្នើសុំការពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់លើសំណើសុំដកថវិកា ដើម្បីយកទៅប្រើប្រាស់សម្រាប់ការសាងសង់អគារ រដ្ឋបាលសាលាខេត្តព្រះសីហនុ
  - បានធ្វើលិខិតគោរពជូនក្រសួងមហាផ្ទៃស្តីពីគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាលលើករណីសំណើដោះ-ដូរទីតាំងដី១កន្លែង ខេត្តតាកែវ
- ការគ្រប់គ្រងប្រមូលចំណូលសាធារណៈ
  - បានបើកផ្តល់បង្កាន់ដៃបង់ប្រាក់សរុបចំនួន ១៣៣៩៦៤ក្បាល ក្នុងនោះសម្រាប់ការប្រើប្រាស់ប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិចំនួន ២១ ៤១៤ ក្បាល និងរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ១១២ ៥៥០ ក្បាល
  - បានបើកផ្តល់ទិដ្ឋាការស្អិតជូនក្រសួងមហាផ្ទៃ សរុបចំនួន ១២០ ០០០សន្លឹក
  - ការប្រមូលចំណូលក្នុងរយៈពេល ៧ខែ ដើមឆ្នាំ២០២២ សម្រេចបាន៨៤១ ៥៩៩,៩ លានរៀល ស្មើនឹង ៧១,០% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២
  - គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ របាយការណ៍ចំណូលខែសីហា ឆ្នាំ២០២២ របស់ក្រសួង ស្ថាប័នប្រមូលបានចំនួន ២០ នៅខ្វះចំនួន ២

- សម្រេចបានប្រកាសអន្តរក្រសួងលេខ៤៩២ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការកែ-សម្រួលការបែងចែកចំណូលពីសេវាសាធារណៈ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- សម្រេចបានប្រកាសអន្តរក្រសួងលេខ៥៣៣ សហវ.ប្រក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការយកកម្រៃសេវាធ្វើតេស្តរហ័សរកអង់ទីហ្សែនកូវីដ-១៩ ចំពោះអ្នកដំណើរជាជនបរទេស ដែលមិនបានចាក់វ៉ាក់-សាំងកូវីដ-១៩ ឬបានចាក់វ៉ាក់សាំងកូវីដ-១៩ ដូសមូលដ្ឋានមិនបានពេញលេញ

- ការគ្រប់គ្រងប្រមូលចំណូលពីសហគ្រាសសាធារណៈ



  - បានធ្វើគម្រោងផែនការថវិកាសម្រាប់ឆ្នាំ២០២២សហគ្រាសសាធារណៈរួមមាន: ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម, អគ្គសនីកម្ពុជា, មន្ទីរពិសោធន៍សំណង់ និងសាធារណការ
  - បានផ្តល់យោបល់លើការកែប្រែលក្ខន្តិកៈ មាត្រាទី៣៤របស់ធនាគារអភិវឌ្ឍជនបទ និង កសិកម្ម
  - ចូលរួមប្រជុំស្តីពីប្រមូលធាតុចូលបន្ថែមលើការកំណត់លក្ខណៈវិនិច្ឆ័យអប្បបរមារបស់គ្រឹះស្ថានសារធារណៈរដ្ឋបាល និងបានផ្តល់យោបល់បន្ថែមលើខ្លឹមសារនៃសេចក្តីព្រាង អំពីលក្ខណៈវិនិច្ឆ័យអប្បបរមានៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
  - បានទំនាក់ទំនងនិងជំរុញសហគ្រាសសាធារណៈត្រូវបង់ប្រាក់ចំណេញ (ភាគលាភ)គិតត្រឹម ៩ខែ ឆ្នាំ២០២២ ទទួលបានភាគលាភនៃប្រាក់ចំណេញចំនួន ១៣ ៧៦១,៥៤ លានរៀល

- ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
  - បានរៀបចំព្រាងផែនការសកម្មភាពធ្វើប័ណ្ណកម្មសិទ្ធិសម្រាប់ក្រសួង ស្ថាប័ន មន្ទីរ រាជធានី ខេត្ត ក្រុងស្រុក ឃុំសង្កាត់ និងនីតិបុគ្គលសាធារណៈ
  - បានបំពេញបេសកកម្មចូលរួមពិនិត្យ ផ្ទផ្ទង និងវាយតម្លៃលើការរៀបចំ និងកាគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ(តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២១) របស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ- សង្កាត់ នៃខេត្តទាំង២៥
  - បានចូលរួមពិនិត្យ និងធ្វើបច្ចុប្បន្នភាពទីតាំងដីរដ្ឋ ដែលបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពុំទាន់មានប័ណ្ណកម្មសិទ្ធិ ដើម្បីកំណត់ព្រំប្រទល់ និងកសាងគំនូសប្លង់ទីតាំង ដើម្បីរៀបចំចេញប័ណ្ណកម្មសិទ្ធិលើដីរដ្ឋសរុប ៩ខេត្ត-រាជធានី

- ○ បានបូកសរុបរបាយការណ៍បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០២០ របស់ក្រសួង-ស្ថាប័ន មន្ទីរ រាជធានី ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងនីតិបុគ្គលសារធារណៈគោរពជូននាយករដ្ឋមន្ត្រី
  - ○ បានបំពេញបេសកកម្មចូលរួមពិនិត្យជាក់ស្តែងនូវចលនទ្រព្យដែលមានសភាពចាស់ទ្រុឌទ្រោម ខូចគុណភាព ដែលក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចបានស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្តត្បូងឃ្មុំ ,កំពង់ធំ និង កំពង់ចាម
  - ○ បានបំពេញបញ្ចាបេសកកម្មចូលរួមពិនិត្យជាក់ស្តែងនូវចលនទ្រព្យដែលមានសភាពចាស់ទ្រុឌទ្រោមខូចគុណភាពដែលក្រសួងកិច្ចការនារី ស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ មន្ទីរកិច្ចការនារីខេត្តរតនគីរី
  - ○ បានបំពេញបេសកកម្មចូលរួមពិនិត្យជាក់ស្តែងនូវចលនទ្រព្យដែលមានសភាពចាស់ទ្រុឌទ្រោម ខូចគុណភាព ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត មណ្ឌលគីរី,កំពង់ធំ,កំពង់ឆ្នាំង និងខេត្តប៉ៃលិន
  - ○ បានបំពេញបេសកកម្មចូលរួមប្រជុំពិនិត្យ និងវាយតម្លៃជាក់ស្តែងនូវអគារចាស់ៗ០១ខ្នង ដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរបរិស្ថានខេត្តកំពង់ធំ
- ការគ្រប់គ្រងចំណូល-បំណុលមិនមែនសារពើពន្ធតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
  - ○ បានពិនិត្យ តាមដានការស្នើសុំ និងបានអនុម័តលេខកូដចំណូលចំនួន ០៥កូដ ក្នុងនោះកូដចំណូលពីកាតព្វកិច្ចកាស៊ីណូ ចំនួន០២កូដ និងចំណូលកាព្វកិច្ចឆ្នោតចំនួន ០៣កូដ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - ○ បានពិនិត្យ តាមដានការស្នើសុំ និងបានអនុម័តលេខកូដចំណូលចំនួន ៦កូដ ក្នុងនោះកូដចំណូលពីការជួលចំនួន ០១កូដ និងចំណូលផ្សេងៗចំនួន ០៥កូដ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
  - ○ បាននិងកំពុងអភិវឌ្ឍនមុខងារចំណូលផ្សេងៗ ចំណូលពីការផាកពិន័យ និងចំណូលពីការជួលដី និងអគារសម្រាប់ប្រើប្រាស់ក្នុងការកត់ត្រាចំណូលរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ○ បានបញ្ចប់ការអភិវឌ្ឍនទម្រង់សលាកបត្រថវិកាថ្នាក់ក្រោមជាតិ ដល់រដ្ឋបាលរាជធានី-ខេត្ត ដែលរួមមានចំណូលពីការជួលដី និងអគារ ចំណូលផ្សេងៗ និងចំណូលពីការផាកពិន័យ
  - ○ បានបញ្ចប់ការអភិវឌ្ឍនមុខងារកត់ត្រាចំណូលផ្សេងៗថ្នាក់ក្រោមជាតិរបស់រដ្ឋបាលរាជធានី ខេត្ត
  - ○ បានធ្វើបច្ចុប្បន្នភាពទិន្នន័យ និងបូកសរុបតួលេខចំណូលមិនមិនសារពើពន្ធថ្នាក់ជាតិឆ្នាំ២០២១ (គិតត្រឹមថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០២២) ដែលមានចំនួន ១ ៩៧០ ៤៩៣ លានរៀល ត្រូវជា ៩០,១៤% ធៀបច្បាប់ឆ្នាំ២០២១
  - ○ បានធ្វើបច្ចុប្បន្នភាពទិន្នន័យ និងបានបូកសរុបតួលេខចំណូលមិនមិនសារពើពន្ធថ្នាក់ជាតិឆ្នាំ២០២២ (គិតត្រឹមថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២) ដែលមានចំនួន ១ ១៩៩ ៧០១,៩៩ លានរៀល ត្រូវជា ៦២,១៥% ធៀបច្បាប់ឆ្នាំ២០២២។

២.២. ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការគ្រប់គ្រងចំណាយសាធារណៈ

ផ្នែកនេះ ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ។ អគ្គនាយកដ្ឋានថវិកាមានបេសកម្មក្នុងការគ្រប់គ្រងថវិកាជាតិហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋក្នុងគោលដៅធានាឱ្យមានការបែងចែកធនធានថវិការដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព[5]។ រីឯ អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល បំពេញបេសកកម្មសំខាន់ លើការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុលរដ្ឋប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងចីរភាព[6]។ អគ្គនាយកដ្ឋានរតនាគារជាតិ មានបេសកកម្មសំខាន់លើ ១. ជាបេឡាករ និងគណនេយ្យករសាធារណៈរបស់រាជរដ្ឋាភិបាល ២.គ្រប់គ្រងប្រាក់កាក់របស់រដ្ឋ និងគណនីពិសេសរបស់រតនាគារ ៣. រៀបចំគោលការណ៍និងបទបញ្ញាគណនេយ្យសាធារណៈ ៤.កាន់កាប់ និងតាមដានការអនុវត្តគណនេយ្យទូទៅ និងមជ្ឈការគណនី ៥.ធានាតុល្យភាពទូទៅនៃគណនី ៦. តម្រង់ទិសនិងតាមដានការអនុវត្តគោលនយោបាយហិរញ្ញវត្ថុ និងបំណុលសាធារណៈ ៧.សហការជាមួយធនាគារជាតិនៃកម្ពុជា ក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ ៨.កសាងសេចក្តីព្រាងច្បាប់សម្រាប់ទូទាត់ថវិកាប្រចាំឆ្នាំ[7]។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈមានបេសកកម្មសំខាន់ លើការគ្រប់គ្រងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់អគ្គនាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ បំពេញបេសកកម្មលើការគ្រប់គ្រង និងការវិភាជថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា។ អង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជនក៏ត្រូវបានអនុវត្តក្នុងផ្នែកនេះផងដែរ។ អង្គភាពនេះជំរុញ សម្របសម្រួល និងគ្រប់គ្រងគម្រោង តាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ជាលទ្ធផលអគ្គនាយកដ្ឋាន និងអង្គភាពបានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

២.២.១. ការគ្រប់គ្រង និងការអនុវត្តថវិកា

- ការរៀបចំថវិកា
  - បានពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងអនុស្សរណៈយោគយល់ នៃជំនួយបច្ចេកទេសរបស់ United Nations Capacity Development Fund
  - បានចូលរួមពិភាក្សាលើប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍវារីវប្បកម្មទឹកសាប និងមជ្ឈមណ្ឌលស្រាវជ្រាវ និងផលិតពូជវារីសត្វមេគង្គលើរបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  - បានរៀបចំរបាយការណ៍ស្តីពីកិច្ចប្រជុំពិភាក្សាលើគោលការណ៍សម្រាប់ការចរចាថវិកាប្រចាំឆ្នាំ ២០២៣



ប្រជុំបូកសរុបលទ្ធផលនៃការរៀបចំថវិកា ២០២៣ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០២២

[5] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[6] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[7] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

        - បានរៀបចំរបាយការណ៍លទ្ធផលនៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២២ ជូនដល់សម្តេចនាយករដ្ឋមន្ត្រី សម្តេចប្រធានរដ្ឋសភា និងសម្តេចប្រធានព្រឹទ្ធសភា

- ការអនុវត្តថវិកា
    - ចំណាយចរន្ត
        - អនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ២០២១ ស្តីពីប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យអនុវត្ត
        - ប្រកាសលេខ០៩៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ២០២១ ស្តីពីវិធាននិងនីតិវិធីអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រូវបានដាក់ឱ្យអនុវត្ត
        - ប្រជុំពិភាក្សាលើការកំណត់យន្តការនិងនីតិវិធីគ្រប់គ្រងចំណាយសម្រាប់ ការរៀបចំការប្រកួតកីឡា អាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣
        - បានពិនិត្យនិងផ្តល់យោបល់លើសំណើសុំគោលការណ៍ធានាចំណាយរបស់ក្រសួងស្ថាប័នចំនួន៣៩ រួមទាំងប្រាក់ឧបត្ថម្ភធនរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ឱ្យស្របតាមបរិបទ FMIS
        - ទិន្នន័យធានាចំណាយ និងការស្នើសុំទូទាត់របស់ក្រសួង ស្ថាប័នទាំងអស់ត្រូវបានចុះចូលក្នុងប្រព័ន្ធ FMIS តាំងពីចំណុចចាប់ផ្តើមរហូតដល់ចំណុចចុងក្រោយ
    - ចំណាយវិនិយោគ
        - ជំពូក២១ (គម្រោងវិនិយោគផ្ទាល់) : បានផ្តល់ធានាចំណាយជូនក្រសួងសាធារណការនិងដឹកជញ្ជូនចំនួន ៤៤គម្រោង ក្រសួងអភិវឌ្ឍន៍ជនបទ សរុបចំនួន ៣៦គម្រោង ក្រសួងធនធានទឹក និងឧតុនិយម សរុបចំនួន ០៩ គម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ០១គម្រោង ក្រសួងមហាផ្ទៃ សរុបចំនួន ០៥គម្រោង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០១គម្រោង ក្រសួងសុខាភិបាលសរុបចំនួន ៣គម្រោង ក្រសួង ស្ថាប័នផ្សេងៗ ចំនួន ១គម្រោង
        - ជំពូក៦១ (ការងារជួសជុលនិងថែទាំ) : បានផ្តល់ធានាចំណាយជូនក្រសួងសាធារណការនិងដឹកជញ្ជូនសរុបចំនួន ៤៥ គម្រោង ក្រសួងធនធានទឹកនិងឧតុនិយម សរុបចំនួន ៦៩ គម្រោង។

២.២.២. ការគ្រប់គ្រងចំណាយសាធារណៈ

- ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ជាតិ
    - ការចុះកិច្ចព្រមព្រៀង ៖គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២
        - ហិរញ្ញប្បទានឥតសំណង៖ បានចុះកិច្ចព្រមព្រៀងចំនួន ១១ គម្រោង មានទឹកប្រាក់សរុបប្រមាណចំនួន ១៣៥,២៦ លានដុល្លារអាមេរិក ដែលមានដូចខាងក្រោម៖
            - ដៃគូអភិវឌ្ឍន៍ពហុភាគី៖ បានចុះកិច្ចព្រមព្រៀងចំនួន ៧ គម្រោង មានទឹកប្រាក់សរុបប្រមាណចំនួន ៤៣,៤៣ លានដុល្លារអាមេរិក
            - ដៃគូអភិវឌ្ឍន៍ទ្វេភាគី៖ បានចុះកិច្ចព្រមព្រៀងចំនួន ៤ គម្រោង មានទឹកប្រាក់សរុបប្រមាណចំនួន ៩១,៨២ លានដុល្លារអាមេរិក

- ឥណទានសម្បទាន÷ បានចុះកិច្ចព្រមព្រៀងចំនួន ១២គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ១ ២១៧,៩០ លានដុល្លារអាមេរិក សមមូលនឹង ៩៤៩,៨៣ លានអេសដេអែរ ស្មើនឹង ៥៩,៣៦% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (១ ៦០០លាន អេសដេអែរ) ដែលមានដូចខាងក្រោមៈ
  - ដៃគូអភិវឌ្ឍន៍ពហុភាគី÷ បានចុះកិច្ចព្រមព្រៀងចំនួន ៥គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ៣៩៣,៣៨ លានដុល្លារអាមេរិក សមមូលនឹង ៣០៦,៧៩ លានអេសដេអែរ ស្មើនឹង ១៩,២០% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (១ ៦០០លាន អេសដេអែរ)
  - ដៃគូអភិវឌ្ឍន៍ទ្វេភាគី÷ បានចុះកិច្ចព្រមព្រៀងចំនួន ៧ គម្រោង ដែលមានទឹកប្រាក់សរុបប្រមាណចំនួន ៨២៤,៥២ លានដុល្លារអាមេរិក សមមូលនឹង ៦៤៣,០៣ លានអេសដេអែរ ស្មើនឹង ៤០,២០% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (១ ៦០០លាន អេសដេអែរ)

○ ការដកសាច់ប្រាក់ ÷ គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២ ÷ បានដកសាច់ប្រាក់សរុបចំនួន ១ ១៤៥,៤៨ លានដុល្លារអាមេរិក ឬ ប្រមាណ ៤ ៦៦០,៤ ប៊ីលានរៀល ស្មើនឹង ៦៥,៨១% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រួមមាន÷
- ហិរញ្ញប្បទានឥតសំណង ÷ បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ៦១,១៧ លានដុល្លារអាមេរិក ឬ ប្រមាណ ២៤៨,៨២ ប៊ីលានរៀល ស្មើនឹង ២៨,៤០% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ឥណទានសម្បទាន÷បានដកសាច់ប្រាក់សរុបចំនួនប្រមាណ ១ ០៨៤,៣០លានដុល្លារអាមេរិក ឬ ប្រមាណ ៤ ៤១១,៥៩ ប៊ីលានរៀល ស្មើនឹង ៧១,០៩% នៃផែនការប្រចាំឆ្នាំ
- ចំណូល-ចំណាយហិរញ្ញប្បទានក្រៅប្រទេស (ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានដែលពុំឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ)÷ អនុវត្តបានចំនួន ៧៥៣,១២ លានដុល្លារអាមេរិក ឬ ប្រមាណ ៣ ០៧០,៦៤ ប៊ីលានរៀល ស្មើនឹង ៥២,៨២% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ (៥ ៨១៣ ៤៨៤លានរៀល)

○ ការទូទាត់សេវាបំណុល (គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២)
- បានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍សរុបចំនួន ១ ៧០៤,៩១ ប៊ីលានរៀល ឬ ប្រមាណ ៤១៧,៩៤ លានដុល្លារអាមេរិក ៨០,២៨% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២
- ការប្រមូលចំណូលពីការឱ្យប្រាក់គេខ្ចីការបោះផ្សាយលក់មូលបត្ររដ្ឋ (គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ ២០២២)
  - បានប្រមូលចំណូលសេវាបំណុលពីឥណទាយិកសរុបចំនួន ១៥០,១៦ ប៊ីលានរៀល ឬ ប្រមាណ ៣៦,៨៣ លានដុល្លារអាមេរិកស្មើនឹង៥៧,៩៦% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២២
  - ការប្រមូលចំណូលពីការបោះផ្សាយលក់មូលបត្ររដ្ឋ(គិតចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២) ÷ ជំពូក ៥០ (កាខ្ចី) គណនី ៥០០៤ (ការខ្ចីពីទីផ្សារហិរញ្ញវត្ថុ) អនុគណនី ៥០៤១ (សញ្ញាប័ណ្ណ) បានប្រមូលចំណូលពីការបោះផ្សាយលក់មូលបត្ររដ្ឋសរុបចំនួន ៤,១៧ ប៊ីលានរៀល ឬ ប្រមាណ ១០,១៥ លានដុល្លារអាមេរិក ស្មើនឹង ០,៣៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ

○ សន្និធិបំណុល÷ តាមការប៉ាន់ស្មាន ដោយគិតបញ្ចូលទាំងបំណុលមរតកកំពុងចរចាដោះស្រាយ គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២ កម្ពុជាមានសន្និធិបំណុលសាធារណៈសរុបចំនួនប្រមាណ ៩ ៥៨៦,១៣ លានដុល្លារអាមេរិក ក្នុងនោះ បំណុលសាធារណៈក្រៅប្រទេស ដែលមានចំនួនប្រមាណ ៩ ៥៧៥,៩៨ លានដុល្លារអាមេរិក ត្រូវនឹង

ប្រមាណ៩៩,៨៩% នៃសន្និធិបំណុលសាធារណៈសរុប និងបំណុលសាធារណៈក្នុងប្រទេស (កើតចេញពីការបោះផ្សាយសញ្ញាប័ណ្ណ) មានចំនួនប្រមាណ ១០,១៥ លានដុល្លារអាមេរិក ត្រូវនឹងប្រមាណ ០,១១% នៃសន្និធិបំណុលសាធារណៈសរុប។ ផ្អែកតាមលទ្ធផលបឋមនៃការវិភាគចីរភាពបំណុលបង្ហាញថា, បើទោះបីជាសេដ្ឋកិច្ចកម្ពុជាទទួលរងនូវផលប៉ះពាល់ពីការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩ និងពីកត្តាខាងក្រៅផ្សេងទៀតក្តី ក៏ស្ថានភាពបំណុលសាធារណៈ កម្ពុជា នៅតែស្ថិតក្នុងភាពអាចគ្រប់គ្រងបាន ពោលគឺ នៅតែមាន «ចីរភាព» និង «ហានិភ័យកម្រិតទាប» ដដែល

- ○ បានពិនិត្យនិងផ្តល់ទិដ្ឋាការលើឯកសារដេញថ្លៃចំនួន ២៧៨គម្រោង និងបានចូលរួមប្រជុំចរចាថ្លៃចំនួន ៤៣៩គម្រោង
- ○ បានចូលរួមប្រជុំបើកឯកសារដេញថ្លៃ (លើសិទ្ធិ)ចំនួន ២៥៧គម្រោង និងបានចូលរួមពិគ្រោះថ្លៃ និងស្ទង់តម្លៃ (ក្រោមសិទ្ធិ)ចំនួន៨៤០ គម្រោង
- ○ បានត្រួតពិនិត្យលើឯកសារកិច្ចសន្យាចំនួន ៥៨៤គម្រោង និងបានប្រគល់កិច្ចសន្យាចំនួន ៣៣៥គម្រោង
- ○ បានពិនិត្យការស្នើសុំគោលការណ៍អនុវត្តកិច្ចលទ្ធកម្មដោយឡែក១៣៣គម្រោង
- ○ បានចូលរួមត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ បញ្ចប់សុពលភាព ប្រគល់-ទទួល ទំនិញ សំណង់ និងសេវាកម្ម (លើសិទ្ធិ) ចំនួន ៩៤០គម្រោង និង(ក្រោមសិទ្ធិ)ចំនួន ៦២០គម្រោង

សិក្ខាសាលាពិគ្រោះយោបល់ប្រមូលធាតុចូលអំពីសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២

- ○ ថ្នាក់ដឹកនាំក្រសួងបានអនុម័តផែនការលទ្ធកម្មកែតម្រូវមានក្រសួងស្ថាប័ន ៦៤ ឯកសារ និង គ្រឹះស្ថាន ១០ ឯកសារ
- ○ បានត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយនៅស្ថាប័នអនុវត្តលទ្ធកម្មថ្នាក់ជាតិចំនួន២០និងអង្គភាពថវិកាថ្នាក់កណ្តាលចំនួន០៦ នៅស្ថាប័នអនុវត្តលទ្ធកម្មរដ្ឋបាលរាជធានីខេត្តចំនួន២១ និងអង្គភាពថវិកាថ្នាក់មូលដ្ឋានចំនួន៤១២ នៅស្ថាប័នអនុវត្តលទ្ធកម្មអង្គភាពស្វយ័តចំនួន២៨ និងនៅស្ថាប័នអនុវត្តលទ្ធកម្មក្រុង ស្រុក ខណ្ឌចំនួន៣៩
- ○ ប្រជុំពិភាក្សាអំពីការធ្វើសន្ធានកម្មរវាងប្រព័ន្ធ នៃការទូទាត់សាច់ប្រាក់ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងប្រព័ន្ធទូទាត់អេឡិចត្រូនិក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ○ ប្រជុំពិនិត្យពិភាក្សាអំពីការរៀបចំសេចក្តីព្រាងសារាចរ និងសេចក្តីជូនដំណឹង ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដំណាក់កាលទី២ ជំហានទី២
- ○ បានបន្តរៀបចំបូកសរុបការងារបិទបញ្ជីចំណូល ចំណាយថវិកាឆ្នាំ២០២១ និងបានចូលរួមកិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអាជ្ញាធរសវនកម្មជាតិ

- ប្រជុំពិភាក្សាអំពីការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងឯកសារឌីជីថលជំនានទី១ដល់រដ្ឋបាលស្រុកនិងរដ្ឋបាលឃុំ ក្នុងគោលដៅជួយពន្លឿនដល់ការអនុវត្តចំណូល ចំណាយថវិការបស់រដ្ឋបាលស្រុក និងរដ្ឋបាលឃុំ
  - រៀបចំកិច្ចប្រជុំស្តីពីវឌ្ឍនភាពនៃការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារប្រចាំត្រីមាសទី១ ដោយមានការចូលរួមពីតំណាងគ្រប់ក្រសួង ស្ថាប័ន និងតំណាងធនាគារពាណិជ្ជដៃគូ
  - ពិនិត្យសេចក្តីណែនាំស្តីពីការដាក់ឱ្យក្រសួង ស្ថាប័ន ចំនួន១០ អនុវត្តនីតិវិធីនៃការបើកផ្តល់ប្រាក់បៀវត្សដោយពុំចាំបាច់មានអាណត្តិបើកប្រាក់
  - បានតាមដានក្រសួង ស្ថាប័នដែលបង្កើតតារាងឧបសម្ពន្ធរជ្ជទេយ្យបុរេប្រទានឆ្នាំ២០២២ និងង្កើតគម្រោងចំណាយប្រាក់បេសកកម្មនៅក្នុងប្រទេស ចំណាយសម្រាប់វគ្គបណ្តុះបណ្តាលសិក្ខាសាលា និងប្រជុំផ្សេងៗ ឆ្នាំ២០២២ ដែលអនុវត្តនីតិវិធីបើកផ្តល់សាច់ប្រាក់មុន
  - រៀបចំប្រកាសស្តីពីការកែសម្រួលការប្រើប្រាស់មាតិកាគណនេយ្យលេខ ៧៥១០ (អតិរេក) ទៅប្រើលេខកូដ០០១ តាងអតិរេក លេខកូដ០០២ តាងអតិរេកដែលជាហិរញ្ញប្បទានសម្រាប់ចំណាយ
- ការគ្រប់គ្រងចំណាយសាធារណៈថ្នាក់ក្រោមជាតិ
  - រៀបចំប្រកាសបន្ថែមឥណទានជូនរដ្ឋបាលក្រុង ស្រុកធានាដោយប្រភព៤%នៃចំណូលសារពើពន្ធរដ្ឋបាលខេត្ត និងបានវិភាជន៍ធនធានបន្ថែមជូនរដ្ឋបាលឃុំ សង្កាត់ ធានាដោយប្រភព ៥% នៃចំណូលសារពើពន្ធរដ្ឋបាលរាជធានី ខេត្ត
  - បោះផ្សាយអាណត្តិឧបត្ថម្ភថវិកាអនុវត្តមុខងារអប់រំនៃរដ្ឋបាលក្រុង ស្រុកទាំង១៤ នៅខេត្តបាត់ដំបង
  - រៀបចំប្រកាសបន្ថែមឥណទានជូនរដ្ឋបាលក្រុងគោលដៅទាំង២៨ សម្រាប់អនុវត្តមុខងារសេវាអនាម័យបរិស្ថាន
  - ចុះសិក្សាការអនុវត្តមុខងារ៥៥ នៃការិយាល័យមន្ទីរជំនាញដែលធ្វើសមាហរណកម្មទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅក្រុង ស្រុក នៃខេត្តកំពង់ចាម ខេត្តកំពត និងខេត្តក្រចេះ
  - រៀបចំប្រកាសបង្កើតក្រុមការងារចំពោះកិច្ចកំណត់ប្រភពចំណូល សម្រាប់បង្កើនធនធានជូនរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ណែនាំរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជំរុញការជ្រើសរើសជំនួយការហិរញ្ញវត្ថុឃុំ សង្កាត់ និងរៀបចំគម្រោងវិនិយោគប្រចាំឆ្នាំដែលប្រើប្រាស់ថវិការដ្ឋ
  - ចុះផ្សព្វផ្សាយសារាចរណែនាំពីនីតិវិធីបច្ចេកទេស ស្តីពីការរៀបចំគម្រោងថវិកាឆ្នាំ២០២៣ និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

២.២.៣. ការគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

- គម្រោងអភិវឌ្ឍកំពង់ផែទេសចរណ៍ខេត្តកំពត
  - បានរៀបចំរបាយការណ៍ស្តីពីកិច្ចប្រជុំអន្តរក្រសួងស្តីពីការអនុវត្តប្រតិបត្តិការ និងការថែទាំសម្រាប់គម្រោងកំពង់ផែទេសចរណ៍ខេត្តកំពត តាមយន្តការ PPP
  - បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព ស្តីពីការរៀបចំអភិវឌ្ឍគម្រោងកំពង់ផែទេសចរណ៍ខេត្តកំពតតាមយន្តការ PPP

  - បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងសម្រាប់រៀបចំអភិវឌ្ឍគម្រោងកំពង់ផែទេសចរណ៍ខេត្តកំពត តាមយន្តការ PPP
- គម្រោងប្រព័ន្ធធារាសាស្ត្រព្រែកប្បាស៖
  - បានរៀបចំផែនការការងារ ដើម្បីជំរុញការអភិវឌ្ឍគម្រោងប្រព័ន្ធធារាសាស្ត្រព្រែកប្បាស
  - បានផ្តល់មតិយោបល់លើរចនាសម្ព័ន្ធក្រុមការងារ នៅក្នុងសេចក្តីសម្រេចស្តីពីការបង្កើតនិងប្រព្រឹត្តទៅនៃផ្នែកគ្រប់គ្រងគម្រោងថែទាំប្រព័ន្ធធារាសាស្ត្រព្រែកប្បាស ស្ថិតនៅខេត្តតាកែវ និងប្រព័ន្ធធារាសាស្ត្រព្រែកពោធិ៍ ស្ថិតនៅខេត្តកំពង់ចាម តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន
- គម្រោងចែកចាយទឹកស្អាត Innovative Decentralized Water Solutions to Provide Safety and Resilience for Residential Water Systems៖បានរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំជាមួយនឹង UNCDF អំពីកម្មវិធី Local Climate Adaptive Living Facility (LoCAL)
- មូលនិធិអភិវឌ្ឍន៍គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន៖បានធ្វើលិខិតសំណើសុំបើកគណនីជាប្រាក់ដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា សម្រាប់គាំទ្រដល់មូលនិធិអភិវឌ្ឍន៍ គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- សំណើគម្រោងគ្រោងរៀបចំអភិវឌ្ឍតាមយន្តការ PPP ពីក្រសួង-ស្ថាប័នសាមី
  - បានរៀបចំតារាងសង្ខេបព័ត៌មាន នៃសំណើគម្រោងពីក្រសួង-ស្ថាប័នសាមីដែលបានដាក់មក MEF ចំនួន ៩០ គម្រោង
  - បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃលិខិតសុំផ្តល់សំណើគម្រោងវិនិយោគសាធារណៈ ដែលគ្រោងនឹងរៀបចំអភិវឌ្ឍតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន
  - បានរៀបចំលិខិតដើម្បីជួបពិភាក្សាអំពីសំណើគម្រោងខាងលើជាមួយក្រសួង-ស្ថាប័នសាមីចំនួន៩
  - បានចូលរួមចុះពិនិត្យគម្រោងកំពង់ផែទេសចរណ៍ខេត្តកំពត តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន
- គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ៖
  - បានចូលរួមកិច្ចប្រជុំប្រចាំខែដើម្បីពិភាក្សាលើវឌ្ឍនភាពការងារ ក្នុងក្របខ័ណ្ឌគម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុនៅក្រសួងសាធារណការ និងដឹកជញ្ជូន
  - បានរៀបចំសំណើសុំការឯកភាព លើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបង្កើតគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចព្រមព្រៀងសម្បទាន គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុរៀបចំព្រឹត្តិការណ៍។

២.៣. ការផ្តល់សេវាគាំទ្រទូទៅ និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចំណុច២.៣.១ ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ដោយអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។ អគ្គលេខាធិការដ្ឋាន មានបេសកកម្មសំខាន់ៗលើ ១.ការផ្តល់សេវាគាំទ្រសម្រាប់ប្រក្រតីភាពនៃដំណើរការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២. សម្របសម្រួលការងាររវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទក្រសួង ពិសេសមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានីខេត្ត ៣. ជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ការបណ្តុះបណ្តាលនិង វិក្រិត្យការ ព័ត៌មានវិទ្យាបណ្ណសារ[8]។ អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍បេសកកម្ម សំខាន់លើការងារដោះស្រាយ

[8] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នានា[9]។ វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បំពេញមុខងារសំខាន់លើការបណ្តុះបណ្តាល និងវិក្រឹត្យការសមត្ថភាពមន្ត្រីរាជការលើមុខជំនាញសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[10]។ ចំណែក ២.៣.២. ត្រូវបានអនុវត្ត និងទទួលខុសត្រូវដោយ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដែលមានបេសកកម្មសំខាន់លើការងារពង្រឹងប្រព័ន្ធគ្រប់គ្រងសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ[11]។ ដោយឡែក ចំណុច ២.៣.៣. មានបេសកកម្មសំខាន់លើការងារធ្វើអធិការកិច្ច លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយប្រើអភិក្រមអធិការកិច្ចផ្អែកលើហានិភ័យ និងអធិការកិច្ចផ្អែកលើករណីសង្ស័យឬបណ្តឹងតវ៉ាជាក់ស្តែង[12]។ ចុងក្រោយ លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម មានមុខងាររៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាសុវត្ថិភាពនីត្យានុកូលភាព នៃការគ្រប់គ្រងនិងការអភិវឌ្ឍ ប្រកបដោយសង្គតិភាព និងចីរភាព នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ជាលទ្ធផល ក្នុង៩ខែ ឆ្នាំ២០២២ អង្គភាពនីមួយៗ បានអនុវត្ត និងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម ÷

២.៣.១. ការផ្តល់សេវាគាំទ្រទូទៅ

កម្រងសម្រង់បទបញ្ញត្តិគតិយុត្តពាក់ព័ន្ធពន្ធដារ

- បានរៀបចំបច្ចុប្បន្នកម្មកម្រងគយនិងរដ្ឋាករកម្ពុជា
- បានរៀបចំសទ្ទានុក្រមដូចខាងក្រោម
  - បច្ចេកសព្ទស្រង់ពីកម្រងពន្ធដារថ្មី
  - បច្ចេកសព្ទបឋមស្រង់ពីកម្រងគយថ្មី
  - បច្ចេកសព្ទគតិយុត្តសុពល
  - បច្ចេកសព្ទគតិយុត្តប្រឹក្សា
- បាននិងកំពុងធ្វើបច្ចុប្បន្នកម្មកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធកិច្ចដំណើរការស្ថាប័ននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បាននិងកំពុងធ្វើកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធសេដ្ឋកិច្ចឌីជីថល
- បានរៀបចំប្រព័ន្ធតាមដាននិងគ្រប់គ្រងលិខិតរដ្ឋបាលនៃក្រុមប្រឹក្សានីតិកម្ម
- បានសិក្សាស្រាវជ្រាវឧត្តមានុវត្តន៍អន្តរជាតិ និងទិដ្ឋភាពកម្ពុជា នៃការផ្ទេរបច្ចេកវិទ្យា
- រៀបចំសៀវភៅណែនាំស្តីពី ការអនុវត្តប្រព័ន្ធសិក្សាពីចម្ងាយ សម្រាប់មន្ត្រីរាជការនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

២.៣.២ ការងារសវនកម្មផ្ទៃក្នុង

- បញ្ចប់ការរៀបចំរបាយការណ៍សវនកម្មផ្ទៃក្នុង នៅអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានថវិកាសម្រាប់ឆ្នាំ២០២១

---

[9] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[10] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[11] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

[12] អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

និងរបាយការណ៍សវនកម្មផ្ទៃក្នុងខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តបន្ទាយមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តមណ្ឌលគីរី ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តរតនគីរី ខេត្តកំពង់ស្ពឺ សម្រាប់ឆ្នាំ២០២២

- បញ្ចប់ការចុះធ្វើសវនកម្មថ្នាក់មូលដ្ឋានសម្រាប់ឆ្នាំ២០២២ នៅខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តបន្ទាយមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តមណ្ឌលគីរី ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តរតនគីរី ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តស្ទឹងត្រែង និងខេត្តកែប
- បញ្ចប់លិខិតជំរុញជុំទី១ ឆ្នាំ២០២២ សម្រាប់ការធ្វើសវនកម្ម នៅខេត្តព្រះសីហនុ ខេត្តបាត់ដំបង ខេត្តកោះកុង ខេត្តបន្ទាយមានជ័យ និងខេត្តត្បូងឃ្មុំ
- បញ្ចប់ការចូលរួមជាមួយទីប្រឹក្សាក្នុងស្រុកក្នុងការធ្វើសវនកម្មលើសមិទ្ធកម្មសាកល្បង និងសវនកម្មលើគម្រោងពីដៃគូអភិវឌ្ឍសាកល្បង នៅក្រសួងចំនួន ៩
- បញ្ចប់ការចុះធ្វើសវនកម្មសាកល្បងលើការអនុវត្តនីតិវិធីថ្មីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្ស ការចំណាយលើបន្ទុកបុគ្គលិកដែលមានគោលរបបច្បាស់លាស់ និងការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបក្នុងក្របខណ្ឌ កសហវ តាមប្រព័ន្ធ FMIS ជាមួយជំនាញការអន្តរជាតិផ្នែកសវនកម្មបច្ចេកវិទ្យាព័ត៌មាន នៃមូលនិធិរូបិយវត្ថុអន្តរជាតិ នៅលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS និងអគ្គនាយកដ្ឋានពាក់ព័ន្ធកំពុងរៀបចំបូកសរុបរបាយការណ៍សវនកម្មផ្ទៃក្នុងឆ្នាំ២០២១ របស់ អសក
- បានទទួលការអនុម័តដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំយន្តការ និងនីតិវិធីការធ្វើសវនកម្មអនុលោមភាព។

២.៣.៣. ការងារអធិការកិច្ច

- បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការរៀបចំសេចក្តីព្រាងនីតិវិធីអធិការកិច្ចហិរញ្ញវត្ថុលើសមិទ្ធកម្ម និងសេចក្តីព្រាងនីតិ-វិធីលម្អិតនៃអធិការកិច្ចហិរញ្ញវត្ថុនៅគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអធិការកិច្ចហិរញ្ញវត្ថុ ជូនដល់អង្គភាពរងអធិការកិច្ចហិរញ្ញវត្ថុរួមមានក្រសួង ស្ថាប័ន និងគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានបញ្ចប់ការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ជំហានទី១ ទៅកាន់រដ្ឋបាលខេត្ត សាលាដំបូង និងបណ្តាមន្ទីរជំនាញនៅរាជធានីភ្នំពេញខេត្តកំពង់ស្ពឺ ខេត្តតាកែវ និងខេត្តព្រៃវែង, វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប, មន្ទីរពេទ្យកុមារជាតិ, មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល, សាកលវិទ្យាល័យស្វាយរៀង និងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុក្នុងការិយបរិច្ឆេទ២០២១ ជំហានទី១ នៅក្រសួងចំនួន២
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ជំហានទី២ទៅកាន់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ សាលាដំបូង និងបណ្តាមន្ទីរជំនាញនៅខេត្តកែប ខេត្តស្វាយរៀង និងខេត្តស្ទឹងត្រែង
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ជំហានទី២ នៅចំនួន១
- បានបញ្ចប់ការចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ជំហានទី១ ទៅកាន់រដ្ឋបាលខេត្តសាលាដំបូង និងបណ្តាមន្ទីរជំនាញនៅខេត្តចំនួន ៥
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ជំហានទី១នៅក្រសួង-ស្ថាប័នចំនួន ៦

- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ជំហានទី២ទៅកាន់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ សាលាដំបូង និងបណ្ដាមន្ទីរជំនាញនៅខេត្តចំនួន ២
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ជំហានទី២ នៅក្រសួងចំនួន៣
- បានបញ្ចប់ការងារអធិការកិច្ចហិរញ្ញវត្ថុនៅក្រសួងចំនួន០៣រួមមានក្រសួងទេសចរណ៍ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធម្មការនិងសាសនា
- បានបញ្ចប់ការងារអធិការកិច្ចហិរញ្ញវត្ថុនៅគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន០៤
- បានបញ្ចប់ការធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈការិយបរិច្ឆេទ២០២១ ជំហានទី១ ចំនួន ៣រដ្ឋបាលខេត្ត ៣សាលាដំបូងខេត្ត មន្ទីរ៥៤ ក្នុង៣ខេត្ត និងអង្គភាពថវិកាចំណុចក្រសួងចំនួន៣ ចំនួន ២ ក្រសួងគឺ ក្រសួងការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងក្រសួងទេសចរណ៍, គ្រឹះស្ថានបោះពុម្ពផ្សាយនៃក្រសួងអប់រំ យុវជន និង កីឡា និងមន្ទីរពិសោធន៍សំណង់ សាធារណៈការ
- បាន និងកំពុងចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុតាមការិយបរិច្ឆេទ២០២១ ជំហានទី២ទៅកាន់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ សាលាដំបូង និងបណ្ដាមន្ទីរជំនាញនៅខេត្តឧត្ដរមានជ័យ ខេត្តមណ្ឌលគិរី និងខេត្តប៉ៃលិន។

៣.ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដោយគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទីចូលរួម អនុវត្ត លើកកម្ពស់ ក្នុងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈគ្រប់ដំណាក់កាល ដើម្បីឱ្យការងារគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ ក្នុងក្រសួង ក៏ដូចជា គ្រប់ក្រសួងស្ថាប័ន កាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព ដូចនេះ ផ្នែកទី៣ នេះ ត្រូវបានអនុវត្ត និងទទួលខុសត្រូវ ពីគ្រប់អង្គភាពទាំងអស់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាលទ្ធផល អង្គភាពបានអនុវត្តនិងទទួលបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចខាងក្រោម÷

- បានរៀបចំកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើប្រធានបទ សិក្ខាសាលាបញ្ជ្រាបការយល់ដឹងកម្រិតផ្ទៃក្នុងស្តីពីគោលការណ៍ណែនាំស្តីពីសវនកម្មអនុលោមភាព

វិបស្សនាកម្មវិធីកែទម្រង់ ៣ បូក ១
ថ្ងៃទី១៣ និងទី១៤ ខែកញ្ញា ឆ្នាំ២០២២

- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការកែសម្រួលផែនការសកម្មភាពលម្អិតនៃយុទ្ធសាស្ត្រគន្លឹះទាំង៤ សម្រាប់អនុវត្តឆ្នាំ ២០២២-២០២៥
- ប្រជុំពិភាក្សាលើការរៀបចំរំហូរនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធទាំងស្រុង ក្នុងក្របខណ្ឌនៃការធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីបញ្ហាប្រឈមនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បានរៀបចំលើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគន្លឹះទាំង៥ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំរបាយការណ៍វឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ២០២១
- បានរៀបចំប្រជុំដើម្បីពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២២ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ចូលរួមផ្តល់យោបល់ និងកែសម្រួលផែនការសកម្មភាពក្នុងយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ និងCAP4
- បានបញ្ចប់ការពិនិត្យនិងកែសម្រួលមុខងារបង្កើតវិក្កយបត្រលើចំណូលពីសម្បទានសេវាសាធារណៈ និងចំណូលពីសម្បទានផលនេសាទដែលអនុវត្តដោយរដ្ឋបាលរាជធានីខេត្តក្នុងប្រព័ន្ធ NRMIS ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់អាចជ្រើសរើសប្រតិបត្តិការបានច្រើននៅក្នុងវិក្កយបត្រតែមួយ
- បានជួបសម្ភាសជាមួយទីប្រឹក្សាបច្ចេកទេសអំពីការរៀបចំ និងអនុវត្តថវិកាដែលឆ្លើយតបនឹងបញ្ហាយេនឌ័រ របស់ក្រុមការងារក្រសួងកិច្ចការនារីនិងទីប្រឹក្សាបច្ចេកទេស ជាមួយក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមការងារគណៈកម្មាធិកាដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានកែសម្រួលផែនការសកម្មភាពលម្អិត សម្រាប់អនុវត្តយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ទៅតាមទម្រង់ថ្មី
- បានរៀបចំបានអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើប្រធានបទ "សិក្ខាសាលាផ្សព្វផ្សាយស្តីពីផែនការអភិវឌ្ឍអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់រយៈពេល ៥ឆ្នាំ (២០២១-២០២៥)"។

សេចក្តីសន្និដ្ឋាន

យោងតាមខ្លឹមសារដូចដែលបានពណ៌នាក្នុងរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំ៩ខែ ឆ្នាំ២០២២ នេះ ពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញពីការបំពេញតួនាទីយ៉ាងសកម្មពីគ្រប់អង្គភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងការងារប្រចាំថ្ងៃ និងការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលលើបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅកម្ពុជា។ ទន្ទឹមគ្នានេះ របាយការណ៍នេះ ក៏បានសបញ្ជាក់ពីបទពិសោធន៍ល្អៗ ចំណុចខ្លាំង និងចំណុចមួយចំនួនតូច ដែលនៅមានការខ្វះខាតក្នុងការអនុវត្តការងាររបស់អង្គភាពនីមួយៗ ដែលនេះអាចជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់ជាមូលដ្ឋានធ្វើការពិនិត្យ តាមដាន វាយតម្លៃ និងកែលម្អ គុណភាពការងារឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគុណភាព ដើម្បីជាកាតាលីករជំរុញគាំទ្រដល់កត្តាកំណត់ភាពជោគជ័យ លើការអនុវត្តការងាររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាចីរកាលតរៀងទៅ។ តាមរយៈនេះ យើងអាចវាយតម្លៃបានថា យន្តការរៀបចំរបាយការណ៍ស្តីពីសកម្មភាពការងារក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានមកពីការប្រមូលសរុបរបាយការណ៍សកម្មភាពការងារនៃគ្រប់អង្គភាពក្រោមឱវាទក្រសួង ពិតជាមានអត្ថប្រយោជន៍ និងគុណតម្លៃខ្ពស់ ដែលប្រៀបដូចជាការត្រួតពិនិត្យតាមដានការអនុវត្តការងារដោយផ្អែកលើសមិទ្ធផលជាក់ស្តែងរបស់អង្គភាពនីមួយៗ និងថែមទាំងបានជះឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលដល់ស្មារតី នៃការអនុវត្តការងាររបស់ថ្នាក់ដឹកនាំ និងបុគ្គលិកមន្ត្រីរាជការនៃគ្រប់អង្គភាពឱ្យកាន់តែខិតខំប្តេជ្ញាចិត្តបំពេញកិច្ចការងារតាមតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនថែមមួយកម្រិតទៀត ហើយវាពិតជាមានសារសំខាន់ណាស់ដែលក្រសួងត្រូវតែបន្តអនុវត្តយន្តការនេះឱ្យបានជាប់ជាប្រចាំ ព្រមទាំងជំរុញកិច្ចការនេះឱ្យកាន់តែមានគុណភាព ប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយបន្ថែមទៀត។

ទោះស្ថិតក្នុងស្ថានភាពនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្តី ក៏ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងនៅតែប្រកាន់គោលជំហរខិតខំប្រឹងប្រែងប្រកបដោយផែនការ និងយន្តការច្បាស់លាស់ ក្នុងភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ចំពោះការបំពេញមុខងារភារកិច្ចរបស់ខ្លួន ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការធានាចីរភាព នៃកំណើនសេដ្ឋកិច្ច និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជា ឱ្យកាន់តែមានវឌ្ឍនភាពរីកចម្រើនទៅមុខជាលំដាប់។ ទន្ទឹមគ្នានេះ ដើម្បីឈានទៅរកការសម្រេចជោគជ័យស្របតាមគោលបំណងគោលនយោបាយរបស់ក្រសួង វាពិតជាចាំបាច់ណាស់ដែលទាមទារឱ្យមានការចូលរួមចំណែកពីគ្រប់អង្គភាពទាំងអស់ក្រោមឱវាទក្រសួង ព្រមទាំងបន្តខិតខំបង្កើនប្រសិទ្ធភាពការងារបន្ថែមទៀត ដោយឈរលើគោលការណ៍តម្កល់ប្រយោជន៍រួមជាធំ ដើម្បីសម្រេចបានសមិទ្ធផលតាមសូចនាករដែលបានគ្រោងទុក ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានកំណត់ទិសដៅសំខាន់ជាយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាតិ ទាំងក្នុងតួនាទីជានិម្មាបនករ និងជាប្រតិបត្តិករ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា។